ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ឯកសារជំនួយ



# ការកំណត់អត្តសញ្ញាណកុមារ
# មានពិការភាព អាយុក្រោម៦ឆ្នាំ

ឆ្នាំ ២០១៩

CRS
CATHOLIC RELIEF SERVICES

រៀបចំដោយ
នាយកដ្ឋានអប់រំពិសេស

# បុព្វកថា

ដើម្បីឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍប្រកបដោយចីរភាពត្រង់ចំណុចទី៤ ការអប់រំបរិយាបន្ន សមធម៌ គុណភាព និងលើកកម្ពស់ការសិក្សាពេញមួយជីវិត សម្រាប់ទាំងអស់គ្នា ក្រសួងអប់រំ យុវជន និងកីឡា បានខិតខំយកចិត្តទុកដាក់លើកកម្ពស់គុណភាពអប់រំ ជាពិសេសបង្កើនអត្រាចុះឈ្មោះចូលរៀន អត្រាឡើងថ្នាក់ និងកាត់បន្ថយអត្រាបោះបង់ការសិក្សា ហើយផ្តោតលើការអនុវត្តសិទ្ធិកុមារជាមូលដ្ឋាន ដែលជានាសមធម៌ នៃការចូលរៀនរបស់កុមារគ្រប់ប្រភេទ។

ក្រោមកិច្ចសហប្រតិបត្តិការ ជាមួយដៃគូអភិវឌ្ឍជាតិ និងអន្តរជាតិ ជាពិសេស ក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយអង្គការស៊ីអារអែស បានចងក្រង **ឯកសារជំនួយ ការកំណត់អត្តសញ្ញាណកុមារមានពិការភាពអាយុក្រោម៦ឆ្នាំ** ដើម្បីលើកកម្ពស់ការយល់ដឹងពីពិការភាព និងផ្តល់កិច្ចអន្តរាគមន៍ទាន់ពេលសម្រាប់កុមារមានពិការភាព។ ឯកសារនេះ មានគោលបំណងបណ្តុះបណ្តាល និងបំប៉នសមត្ថភាពគ្រូមត្តេយ្យសិក្សា និងអ្នកពាក់ព័ន្ធឱ្យមានចំណេះដឹងនិងបំណិន ក្នុងការកំណត់អត្តសញ្ញាណកុមារមានពិការភាព និងបញ្ជូនទៅរកសេវា គាំទ្រដល់ការអភិវឌ្ឍបំណិនរបស់កុមារ ដើម្បីបានបន្តការចូលរៀនថ្នាក់ទី១។

ក្រសួងអប់រំ យុវជន និងកីឡា សូមថ្លែងអំណរគុណដល់អង្គការស៊ីអារអែស និងដៃគូអភិវឌ្ឍនានា ដែលបានសហការ និងខិតខំប្រឹងប្រែងទាំងកម្លាំងកាយ កម្លាំងចិត្ត ក្នុងការចងក្រងឯកសារជំនួយស្មារតីនេះ ដើម្បីឱ្យកុមារទទួលបានសេវាការអប់រំ ប្រកបដោយបរិយាបន្ន សមធម៌ គុណភាព និងលើកកម្ពស់ការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។

ខ្ញុំសូមលើកទឹកចិត្ត ឱ្យគ្រប់ភាគីពាក់ព័ន្ធទាំងអស់ប្រើប្រាស់ឯកសារជំនួយស្មារតីនេះ សម្រាប់ជាមូលដ្ឋានជួយគាំទ្រដល់កុមារតូច និងកុមារមានពិការភាព ដើម្បីរួមចំណែកសម្រេចបានគោលនយោបាយស្តីពីការអប់រំបរិយាបន្ន និងឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍប្រកបដោយចីរភាព។

ថ្ងៃ ពុធ ៣កើត ខែ កត្តិក ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ២០១៩

**រដ្ឋមន្ត្រីក្រសួង អប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

# អារម្ភកថា

ក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយអង្គការស៊ីអារអែស ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធបានចងក្រងឯកសារជំនួយ ការកំណត់អត្តសញ្ញាណកុមារមានពិការភាព អាយុក្រោម៦ឆ្នាំ។ គោលបំណងនៃការរៀបចំឯកសារជំនួយនេះ គឺដើម្បីលើកកម្ពស់សុខភាព និងស្មារតីកាយសម្បទារ របស់កុមារមានពិការភាព ឱ្យបានប្រសើរឡើង សម្រាប់ជាជំនួយដល់ការសិក្សា និងការរស់នៅប្រចាំថ្ងៃ។

ខ្លឹមសារនៃឯកសារជំនួយនេះ គឺបង្ហាញវិធីងាយៗ សម្រាប់ជំនួយដល់គណៈកម្មការគ្រប់គ្រងសាលារៀន គ្រូមត្តេយ្យសិក្សា និងមាតាបិតា ឬអ្នកអាណាព្យាបាលកុមារ ក្នុងការកំណត់អត្តសញ្ញាណកុមារ និងបញ្ជូនកុមារមានពិការភាពទៅរកសេវាគាំទ្រទាន់ពេលវេលា ដើម្បីអភិវឌ្ឍន៍បំណិនរបស់កុមារ។

គណៈកម្មការរៀបរៀងយើងខ្ញុំ សូមស្វាគមន៍រាល់មតិយោបល់ រិះគន់ស្ថាបនា ពីសំណាក់លោកគ្រូ អ្នកគ្រូ ដោយក្តីសោមនស្សរីករាយ ដើម្បីរួមចំណែកការកំណត់អត្តសញ្ញាណកុមារ និងផ្តល់កិច្ចអន្តរាគមន៍ទាន់ពេលវេលា។

គណៈកម្មការរៀបរៀងឯកសារ

# ក្រុមការងារ ឯកសារ សមាសភាពក្រុមការងារបច្ចេកទេស

ក. គណៈកម្មការគ្រប់គ្រង

១. ឯកឧត្តម ពុត សាមិត្ត អគ្គនាយក នៃអគ្គនាយកដ្ឋានអប់រំ
២. លោក ថោង រិទ្ធី ប្រធាននាយកដ្ឋានអប់រំពិសេស

ខ. គណៈកម្មការ ត្រួតពិនិត្យ

១. លោក ទឹម សាហែន អនុប្រធាននាយកដ្ឋានអប់រំពិសេស
២. លោក វេន វី នាយករងវិទ្យាស្ថានជាតិអប់រំពិសេស
៣. លោក អៀត វុទ្ធី ប្រធានការិយាល័យ នាយកដ្ឋានអប់រំពិសេស
៤. លោកស្រី ម៉ៅ ណារី ប្រធានការិយាល័យ នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ
៥. លោកស្រី ម៉ៅ តាន់ណារី ប្រធានការិយាល័យ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា
៦. លោក ហ៊ឹម សារិន អនុប្រធានការិយាល័យ នាយកដ្ឋានអប់រំពិសេស
៧. លោក ប៉ែន ចាន់កាណាប់ អនុប្រធានការិយាល័យ នាយកដ្ឋានអប់រំពិសេស
៨. លោក ព្រំ វិចិត្រ អនុប្រធានការិយាល័យ នាយកដ្ឋានអប់រំកុមារតូច
៩. លោកស្រី កែ ប៉ា នាយិការងសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម
១០.លោក សៀន កុសល មន្ត្រីឯកទេសអប់រំអង្គការស៊ីអារអេស CRS

គ. ក្រុមការងារ កសាងឯកសារ

១. លោក សរ សារិន ប្រធានការិយាល័យ នាយកដ្ឋានជានាគុណភាពអប់រំ
២. លោកស្រី សុខ សោភា ប្រធានការិយាល័យ នាយកដ្ឋានអប់រំកុមារតូច
៣. លោក ចេក ចាន់នី ប្រធានស្តីទីផ្នែកសមាហរណកម្មជនពិការនៃក្រុមប្រឹក្សាសកម្មភាពជនពិការ
៤. លោក យូ ហារ អនុប្រធានការិយាល័យ នាយកដ្ឋានជានាគុណភាពអប់រំ
៦. លោកស្រី ព្រំ ចាន់មករា អនុប្រធានការិយាល័យ នាយកដ្ឋានអប់រំកុមារតូច
៧. លោក ងិន វុត មន្ត្រីនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ
៨. លោកស្រី នូ ថាវី មន្ត្រីនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ
៩.លោកស្រី សេង ពិសិដ្ឋនារី មន្ត្រី នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា
១០.លោក ដួង ហៃ មន្ត្រីនាយកដ្ឋានបឋមសិក្សា
១១.លោក វេង រដ្ឋ មន្ត្រីនាយកដ្ឋានសុខភាពសិក្សា
១២.លោក ម៉ែន ថារ៉ូ មន្ត្រីនា.សុខមាលភាពជនពិការ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

១៣.លោក ប៉ាត គឹមនីន នាយកសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម

១៤.លោក ងិន សៅភិរក្ស ប្រធានការិយាល័យ សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម

១៥.លោកស្រី ជ្រិះ គន្ធី គ្រូឧទ្ទេសសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម

១៦.លោកស្រី ស្រី កល្យាណ មន្ត្រីវិទ្យាស្ថានជាតិអប់រំពិសេស

១៧.លោកស្រី ព្រីង គឹមនី គ្រូពេទ្យភ្នែក នៃមន្ទីរពេទ្យភ្នែកតាកែវ អង្គការការីតាសកម្ពុជា

១៨.លោក កុំ គិនម៉ៃ មន្ត្រីគម្រោងអប់រំ អង្គការ ស៊ីអារអែស

១៩.មន្ត្រីបច្ចេកទេស តំណាងអង្គការអូអាយស៊ី OiC

២០.មន្ត្រីបច្ចេកទេស តំណាងអង្គការ អេអេអារ ជប៉ុន AAR-Japan

២១.មន្ត្រីបច្ចេកទេស តំណាងអង្គការ អេចអេចស៊ី HHC

២២.មន្ត្រីបច្ចេកទេស តំណាង CCAMH អង្គការកាវីតាសកម្ពុជា

២៣.មន្ត្រីបច្ចេកទេស តំណាងអង្គការ HI



# មាតិកា


| | |
|---|---|
| បុព្វកថា | i |
| អារម្ភកថា | ii |
| ក្រុមការងារ ឯកសារ សមាសភាពក្រុមការងារបច្ចេកទេ | iii |
| មាតិកា | v |
| សារតារ | ១ |
| គោលបំណង | ២ |
| គោលដៅ | ២ |
| ដំណើរការ ដ៏មានប្រសិទ្ធភាព សម្រាប់កំណត់អត្តសញ្ញាណ និងបញ្ជូនកុមារមានពិការភាព ទៅរកសេវា | ៣ |
| តួនាទី និង ភារកិច្ចរបស់អ្នកពាក់ព័ន្ធ | ៦ |
| ការអនុវត្ត ការកំណត់អត្តសញ្ញាណកុមារ មានបញ្ហាស្តាប់ | ៨ |
| ការអនុវត្ត ការកំណត់អត្តសញ្ញាណកុមារ មានបញ្ហានិយាយ | ១៣ |
| ការអនុវត្ត ការកំណត់អត្តសញ្ញាណ កុមារ មានបញ្ហាសតិបញ្ញា | ១៧ |
| ការអនុវត្ត ការកំណត់អត្តសញ្ញាណ កុមារ មានបញ្ហាមើល | ២៣ |
| ការអនុវត្ត ការកំណត់អត្តសញ្ញាណ កុមារ មានបញ្ហាចលនា | ២៩ |
| ឧបសម្ពន្ធ | ៣៣ |
| ឧបសម្ពន្ធ១៖ ដ្យាក្រាម ជំហាននៃការកំណត់អត្តសញ្ញាណកុមារមានពិការភាព | ៣៣ |
| ឧបសម្ពន្ធ២៖ សេវាសម្រាប់កុមារ មានពិការភាព និងជនមានពិការភាព | ៣៤ |
| ឧបសម្ពន្ធ៣៖ | ៣៧ |
| ឧបសម្ពន្ធ៤៖ បញ្ជីឈ្មោះកុមារ ត្រូវបញ្ជូនទៅរកសេវា | ៣៨ |
| ឧបសម្ពន្ធ៥៖ លិខិតជូនដំណឹង គំរូទី១ និងទី២ | ៣៩ |
| ឧបសម្ពន្ធ៦៖បញ្ជីតាមដានកុមារមានពិការភាព | ៤១ |

# សារូបករ

អង្គការស៊ីអារអែស បានអនុវត្តសាកល្បង គម្រោងផ្តល់កិច្ចអន្តរាគមន៍ទាន់ពេល និងការអប់រំ សម្រាប់កុមារមានពិការភាព នៅកម្រិតមត្តេយ្យសិក្សា នៅក្នុងសាលារៀនគោលដៅចំនួន៩ នៅក្នុងស្រុកចំនួន៣ ក្នុងខេត្តតាកែវ ចាប់ពីខែមករា ឆ្នាំ២០១៦ ដល់ខែកញ្ញា ឆ្នាំ២០១៧។ ផ្អែកលើលទ្ធផលនៃការវាយតម្លៃគម្រោង និងកិច្ចប្រជុំពិគ្រោះយោបល់ជាមួយនាយកដ្ឋានអប់រំកុមារតូច នាយកដ្ឋានអប់រំពិសេស និងនាយកដ្ឋានសុខភាពសិក្សា អង្គការស៊ីអារអែស បានកំណត់ចំណុចអាទិភាពចម្បងៗ សម្រាប់ជួយគាំទ្រកុមារអាយុ៣-៥ឆ្នាំ ដើម្បីជួយកុមារត្រៀមខ្លួនចូលរៀន ពីមត្តេយ្យសិក្សាឆ្លងទៅកម្រិតបឋមសិក្សា។ គម្រោងផ្តោតចំណុចសំខាន់ៗចំនួនពីរ៖ ១) រៀបរៀងឯកសារជំនួយស្មារតី ការកំណត់អត្តសញ្ញាណកុមារមានពិការភាព អាយុក្រោម៦ឆ្នាំ និង២) បង្កើតឯកសារជំនួយស្មារតី គំរូល្បែងសិក្សាបរិយាបន្នសម្រាប់គ្រូមត្តេយ្យសិក្សា។ ដោយមានកិច្ចសហការ និងគាំទ្រពីក្រសួងអប់រំ យុវជន និងកីឡា អង្គការស៊ីអារអែស បានធ្វើកិច្ចសហប្រតិបត្តិការ ជាមួយនាយកដ្ឋានអប់រំពិសេស ដឹកនាំដំណើរការនិងរៀបរៀងឯកសារជំនួយការកំណត់អត្តសញ្ញាណកុមារមានពិការភាព ហើយបានបង្កើតក្រុមការងារបច្ចេកទេស ដែលមានសមាជិកសរុបចំនួន៣៩នាក់ ដោយមានការចូលរួមពីនាយកដ្ឋានពាក់ព័ន្ធ របស់ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងដៃគូអភិវឌ្ឍនានា។ គណៈកម្មការរៀបរៀងឯកសារ បានរៀបចំកិច្ចប្រជុំ និងសិក្ខាសាលាជាបន្តបន្ទាប់ ដោយបានប្រជុំពិនិត្យលើឧបករណ៍កំណត់អត្តសញ្ញាណមានស្រាប់ បានជ្រើសរើសឧបករណ៍ដែលសមស្របបំផុតសម្រាប់កុមារមត្តេយ្យ។ បានចងក្រងឧបករណ៍ កំណត់អត្តសញ្ញាណកុមារមានពិការភាព ចំនួន៥ប្រភេទ (បញ្ហាមើល បញ្ហាស្តាប់ បញ្ហានិយាយ បញ្ហាចលនានិងបញ្ហាសតិបញ្ញា)។ បានរៀបចំសិក្ខាសាលា ដើម្បីសរសេរសេចក្តីព្រាងស្តីពីឯកសារជំនួយស្មារតី ការកំណត់អត្តសញ្ញាណកុមារមានពិការភាព។ បានរៀបចំសិក្ខាសាលាជាបន្តបន្ទាប់ ដើម្បីប្រមូលធាតុចូល និងព័ត៌មានត្រឡប់ ដើម្បីពិនិត្យបញ្ចប់ឯកសារជំនួយស្មារតីទាំងស្រុង។

គណៈកម្មការបានបើកវគ្គបំប៉ន ស្តីពីការកំណត់អត្តសញ្ញាណកុមារចំនួនពីរវគ្គ៖ ទី១ សម្រាប់អ្នកពាក់ព័ន្ធ មន្ត្រីបច្ចេកទេសបង្គោលថ្នាក់ជាតិ ថ្នាក់ខេត្តនិងថ្នាក់ស្រុក និងទី២ សម្រាប់គណៈគ្រប់គ្រង សាលារៀន គ្រូមត្តេយ្យសិក្សា និងមន្ត្រីមណ្ឌលសុខភាព។ គណៈគ្រប់គ្រងសាលារៀន និងគ្រូមត្តេយ្យសិក្សា បានសហការជាមួយ និងមន្ត្រីមណ្ឌលសុខភាព ដើម្បីអនុវត្តការកំណត់អត្តសញ្ញាណកុមារមានពិការភាព នៅក្នុងសាលារៀនចំនួន១២ នៅក្នុងស្រុកសំរោង ព្រៃកប្បាស ត្រាំកក់ ខេត្តតាកែវ និងស្រុកឈូក ជុំគីរី ខេត្តកំពត។

# គោលបំណង

លើកកម្ពស់ការផ្ដល់សេវាសុខភាព ដើម្បីកាត់បន្ថយកុមារមានពិការភាព នៅកម្រិតមត្តេយ្យសិក្សា និងអនុវត្តសិទ្ធិកុមារជាមូលដ្ឋាន ដែលជានាសមធម៌ នៃការចូលរៀនរបស់កុមារគ្រប់រូប។

# គោលដៅ

១. ពង្រឹងសមត្ថភាពគណៈកម្មការគ្រប់គ្រងសាលារៀន គ្រូមត្តេយ្យសិក្សា និងអ្នកពាក់ព័ន្ធ ក្នុងការអនុវត្តការកំណត់អត្តសញ្ញាណកុមារនៅតាមសាលារៀន និងបញ្ជូនកុមារមានពិការភាពទៅរកសេវាសមស្រប។

២. បង្កើតបានយន្តការប្រកបដោយគុណភាព និងនិរន្តរភាព ដើម្បីអនុវត្តការកំណត់អត្តសញ្ញាណកុមារ និងបញ្ជូនកុមារមានពិការភាពទៅរកសេវា។

៣. អ្នកពាក់ព័ន្ធ សហការអនុវត្តកំណត់អត្តសញ្ញាណកុមារមានពិការភាព និងផ្តល់កិច្ចអន្តរាគមន៍ទាន់ពេលសម្រាប់កុមារមានពិការភាព។

# ដំណើរការ ដ៏មានប្រសិទ្ធភាព សម្រាប់កំណត់អត្តសញ្ញាណ និងបញ្ជូនកុមារមានពិការភាពទៅរកសេវា

### ១. ការរៀបចំក្រុមការងារសម្រាប់បញ្ជូនកុមារទៅរកសេវា និងតាមដានកុមារ

ក. នាយក ឬនាយករងទទួលបន្ទុក

ខ. គ្រូទទួលបន្ទុកសុខភាពសិក្សា

គ. អ្នកស្ម័គ្រចិត្តសុខភាពភូមិ

ឃ. តំណាងមាតាបិតា ឬអ្នកអាណាព្យាបាល

ង. ទទួលបានការណែនាំអំពីនីតិវិធីនៃការបញ្ជូន និងការប្រើប្រាស់សៀវភៅណែនាំ សម្រាប់បញ្ជូនកុមារទៅរកសេវា។

### ២. ចំប៉ងក្រុមគោលដៅ ស្ដីពីការកំណត់អត្តសញ្ញាណ ឬធ្វើតេស្តរកពិការភាព

ក. នាយក ឬនាយករង ទទួលបន្ទុកសុខភាពសិក្សា

ខ. គ្រូទទួលបន្ទុកសុខភាពសិក្សា

គ. ប្រធានក្រុមបច្ចេកទេស មត្តេយ្យសិក្សា

ឃ. មន្ត្រី នៃមណ្ឌលសុខភាព

ង. គ្រូមត្តេយ្យសិក្សា

### ៣. ការអនុវត្ត ការកំណត់អត្តសញ្ញាណ និងការធ្វើតេស្តរកពិការភាពតាមសាលារៀន

អ្នកចូលរួមកំណត់អត្តសញ្ញាណ

ក. នាយក ឬនាយករង ទទួលបន្ទុកសុខភាពសិក្សា

ខ. គ្រូទទួលបន្ទុកសុខភាពសិក្សា

គ. ប្រធានក្រុមបច្ចេកទេស គ្រូមត្តេយ្យសិក្សា ឬគ្រូបង្គោលមត្តេយ្យសិក្សា

ឃ. មន្ត្រីមណ្ឌលសុខភាព

### ដំណើរការនៃការកំណត់អត្តសញ្ញាណ

- ក. ធ្វើតេស្តបឋមជាមួយកុមារមត្តេយ្យសិក្សាទាំងអស់ កំណត់រកកុមារដែលមានការសង្ស័យថាមានពិការភាព តាមរយៈការសួរសំណួរ និងឱ្យកុមារធ្វើសកម្មភាពមួយចំនួន
- ខ. ការកំណត់អត្តសញ្ញាណ ឬការធ្វើតេស្តលម្អិតលើកុមារដែលសង្ស័យថាមានពិការភាព ហើយបំពេញក្នុងកម្រងសំណួរ

ចំណាំៈ ការកំណត់អត្តសញ្ញាណ ឬការធ្វើតេស្តរកពិការភាព នៅក្នុងសាលារៀននីមួយៗ គឺប្រើរយៈពេលកំណត់មួយ (អាចត្រឹមតែ ១-៣ ថ្ងៃ) ហើយត្រូវធ្វើឱ្យបានចប់សព្វគ្រប់ ជៀសវាងការប្រើពេលច្រើនដង ព្រោះវានឹងរំខានការរៀនរបស់កុមារ។

# លំហូរនៃការកំណត់អត្តសញ្ញាណ

ក. ការកំណត់អត្តសញ្ញាណបឋមៈ ការធ្វើតេស្តកុមារទាំងអស់ ដើម្បីកំណត់រកកុមារដែលសង្ស័យថាមានពិការភាព




ខ. ការកំណត់អត្តសញ្ញាណលម្អិតៈ

ក្រុមការងារធ្វើតេស្តលម្អិត លើកុមារដែលសង្ស័យថាមានពិការភាព។ ក្រុមការងារធ្វើតេស្តត្រូវប្រើប្រាស់ឧបករណ៍ និងបំពេញកម្រងសំណួរទាក់ទងនឹងពិការភាពទាំង៥ប្រភេទ។

## ៤. ការបញ្ជូនកុមារមានពិការភាពទៅរកសេវា

ក. គ្រូទទួលបន្ទុកសុខភាពសិក្សា ឬអ្នកស្ម័គ្រចិត្តសុខភាពភូមិទទួលបន្ទុកជួយបញ្ជូន លើកទី១ ឬ២

ខ. មាតាបិតាសិស្ស ឬអ្នកអាណាព្យាបាលសិស្សមានពិការភាពត្រូវចូលរួមក្នុងដំណើរការបញ្ជូន

គ. អ្នកអាណាព្យាបាលសិស្សមានពិការភាពត្រូវបញ្ជូនកូនតាមការណាត់របស់គ្រូពេទ្យ

ឃ. អ្នកផ្តល់សេវាកត់ត្រាលទ្ធផលនៃការពិនិត្យសុខភាពចូលក្នុងសៀវភៅកំណត់ត្រា ការបញ្ជូនរបស់សិស្ស

## ៥. ការតាមដានក្រោយពេលបញ្ជូន កុមារមានពិការភាពទៅរកសេវា

ក. កត់ត្រារបាយការណ៍លទ្ធផលបញ្ជូនសម្រាប់សាលារៀន

ខ. អ្នកអាណាព្យាបាលសិស្សត្រូវសហការ និងចូលរួមជាមួយសាលារៀនក្នុងការបញ្ជូនកុមារទៅរកសេវា

គ. អ្នកអាណាព្យាបាលសិស្ស រក្សាទុកសៀវភៅកត់ត្រាការបញ្ជូន

ឃ. កំណត់ថ្ងៃបញ្ជូនសម្រាប់ជំហានបន្ទាប់

## ៦. ប្រភពថវិកាគាំទ្រសម្រាប់ការបញ្ជូនកុមារមានពិការភាពទៅរកសេវា

ការបញ្ជូនកុមារមានពិការភាពទៅរកសេវា គឺជាកិច្ចការចាំបាច់ និងបន្ទាន់បំផុតដែលសាលារៀន និងគ្រូសារត្រូវធ្វើ។ វាពិតជាមិនបានផ្តល់អត្ថប្រយោជន៍ឱ្យកុមារនោះទេ ប្រសិនបើកុមារមានពិការភាពត្រូវបានកំណត់រកឃើញ ប៉ុន្តែមិនបានបញ្ជូនពួកគេទៅរកសេវាសុខភាព។

ដើម្បីអាចបញ្ជូនកុមារមានពិការភាពទៅរកសេវាបាន សាលារៀននីមួយៗត្រូវធ្វើផែនការប្រើប្រាស់ប្រភពថវិកាពីខាងក្នុង និងខាងក្រៅ ដូចខាងក្រោម៖

ក) ប្រភពថវិកាពីរាជរដ្ឋាភិបាល៖

- ថវិការបស់សាលារៀន (ថវិកា PB ឬ SOB ឬ ថវិកាហិបសង្គ្រោះរបស់សាលារៀន)
- ថវិកាគាំទ្រ ពីឃុំ/សង្កាត់

ខ) ប្រភពថវិកាពីដៃគូអភិវឌ្ឍ៖

- ថវិកាពីសប្បុរសជន
- ថវិការបស់ដៃគូអភិវឌ្ឍ



# តួនាទី និង ភារកិច្ចរបស់អ្នកពាក់ព័ន្ធ

## តួនាទី និងភារកិច្ច

ដើម្បីអនុវត្តការកំណត់អត្តសញ្ញាណកុមារនៅតាមសាលារៀនដំណើរការបានល្អ និងមានប្រសិទ្ធភាពខ្ពស់គ្រប់អ្នកពាក់ព័ន្ធ ត្រូវមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

### ១. មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត

- ត្រូវរៀបចំលិខិតបទដ្ឋានផ្សេងៗ សហការការជាមួយមន្ទីរសុខាភិបាលសំដៅការអនុវត្តការកំណត់អត្តសញ្ញាណកុមារ និងការធ្វើតេស្តទទួលបានលទ្ធផលល្អ
- ណែនាំបន្តដល់ថ្នាក់ក្រុង ស្រុក ខណ្ឌ និងសាលារៀនក្រោមឱវាទដោយសហការជាមួយមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក ឬមន្ទីរពេទ្យខេត្ត ក្នុងការបញ្ជូនកុមារទៅរកសេវាព្យាបាល និងថែទាំនៅមណ្ឌលស្តារលទ្ធភាពពលកម្ម និងកាយសម្បទា
- ចាត់តាំងមន្ត្រីទទួលបន្ទុកសុខភាពសិក្សា ដើម្បីចូលរួមអនុវត្តដោយសហការជាមួយមន្ត្រីទទួលបន្ទុកការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាល ក្រុង ស្រុក ខណ្ឌ និងមន្ត្រីពាក់ព័ន្ធដទៃទៀត
- តាមដាន សម្របសម្រួល បូកសរុប និងធ្វើរបាយការណ៍លទ្ធផលនៃការកំណត់អត្តសញ្ញាណកុមារមានពិការភាពផ្ញើទៅនាយកដ្ឋានអប់រំពិសេស និងនាយកដ្ឋានសុខភាពសិក្សា។

### ២. ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ

- ណែនាំដល់សាលារៀនក្រោមឱវាទក្នុងការអនុវត្តការកំណត់អត្តសញ្ញាណកុមារមានពិការភាពដោយសហការជាមួយអ្នកពាក់ព័ន្ធ និងមណ្ឌលសុខភាព
- ចាត់តាំងមន្ត្រីទទួលបន្ទុកសុខភាពសិក្សា ដើម្បីចូលរួមសហការជាមួយគណៈគ្រប់គ្រងនៅតាមសាលារៀន និងអ្នកពាក់ព័ន្ធ
- តាមដាន សម្របសម្រួល បូកសរុប និងធ្វើរបាយណ៍ការលទ្ធផលនៃការកំណត់អត្តសញ្ញាណកុមារមានពិការភាពផ្ញើជូនមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត

### ៣. នាយក ឬគណៈកម្មការគ្រប់គ្រងសាលារៀន

- ធ្វើបច្ចុប្បន្នកម្ម និងផ្តល់ព័ត៌មានពីចំនួនសិស្សឱ្យបានច្បាស់លាស់
- សិក្សាស្វែងយល់ពីគោលការណ៍ណែនាំ ស្តីពីការកំណត់អត្តសញ្ញាណកុមារមានពិការភាពឱ្យបានច្បាស់លាស់

- រៀបចំផែនការ និងកាលវិភាគជាក់លាក់សម្រាប់ការអនុវត្តការកំណត់អត្តសញ្ញាណកុមារមានពិការភាពដោយសហការជាមួយគ្រូប្រចាំថ្នាក់ មាតាបិតា និងអ្នកពាក់ព័ន្ធដទៃទៀត
- ពិនិត្យតាមដាន សម្របសម្រួលការអនុវត្ត និងធានាថា កុមារទាំងអស់បានទទួលការធ្វើតេស្ត
- សហការជាមួយមាតាបិតា ឬអ្នកអាណាព្យាបាលកុមារ ដើម្បីស្វែងរកសេវាថែទាំ និងព្យាបាល
- រៀបចំធ្វើលិខិតបញ្ជូនកុមារមានបញ្ហាសុខភាព ឬភាពកម្សោយ ផ្នែកណាមួយ
- បូកសរុបលទ្ធផល និងផ្តល់របាយការណ៍ជូនការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាល ក្រុង ស្រុក ខណ្ឌ

## ៤. គ្រូបង្រៀន

- ណែនាំកុមារឱ្យចូលរួមសកម្មភាពធ្វើតេស្ត ដើម្បីកំណត់រកបញ្ហាសុខភាព ឬភាពកម្សោយ
- សម្របសម្រួល គ្រប់គ្រងសកម្មភាព និងធានាថា កុមារទាំងអស់បានទទួលការធ្វើតេស្ត
- សហការជាមួយមាតាបិតា ឬអ្នកអាណាព្យាបាល និងលើកទឹកចិត្តកុមារឱ្យទៅទទួលសេវាព្យាបាល ក្នុងករណីរកឃើញថាមានបញ្ហាសុខភាព ឬភាពកម្សោយ ផ្នែកណាមួយ
- ផ្តល់របាយការណ៍លទ្ធផលនៃការធ្វើតេស្ត ដល់នាយកសាលា

## ៥. កុមារ

- ចូលរួមក្នុងសកម្មភាពធ្វើតេស្ត ឱ្យបានគ្រប់ៗគ្នាតាមការកំណត់របស់សាលារៀន គ្រូបង្រៀនប្រចាំថ្នាក់
- នាំយកលទ្ធផលនៃការធ្វើតេស្តរបស់ខ្លួន ជូនដល់មាតាបិតា ឬអ្នកអាណាព្យាបាល និងត្រូវទៅទទួលសេវាព្យាបាលក្នុងករណីមានបញ្ហាសុខភាព ឬភាពកម្សោយនៃផ្នែកណាមួយ

## ៦. មាតាបិតា ឬអ្នកអាណាព្យាបាល និងសហគមន៍

- អនុញ្ញាតឱ្យកូនរបស់ខ្លួនបានមកទទួលការធ្វើតេស្តតាមការកំណត់របស់សាលារៀន
- បញ្ជូនកូនទៅមន្ទីរពេទ្យ ឬសេវាថែទាំសុខភាពឱ្យបានទាន់ពេលវេលា ប្រសិនបើកូនមានបញ្ហាសុខភាព ឬភាពកម្សោយនៃផ្នែកណាមួយ

# ការអនុវត្ត ការកំណត់អត្តសញ្ញាណកុមារ មានបញ្ហាស្តាប់

## ចក្ខុបំណង៖

- ពង្រឹងសមត្ថភាពគ្រូ ក្នុងការកំណត់អត្តសញ្ញាណកុមារ មានបញ្ហាស្តាប់
- ផ្តល់ព័ត៌មាន និងស្វែងរកសេវាគាំទ្រសមស្រប បានទាន់ពេលវេលា
- បង្កើន និងពង្រឹងយន្តការវាស់កម្រិតនៃការស្តាប់របស់កុមារ នៅតាមសាលារៀនប្រកបដោយមានប្រសិទ្ធភាព និងនិរន្តរភាព។

## ជំហានក្នុងការកំណត់អត្តសញ្ញាណ កុមារមានបញ្ហាស្តាប់

## ជំហានទី១៖ ពិនិត្យឧបករណ៍ និងរៀបចំសម្ភារៈ

- ប្រជុំពិភាក្សានិងធ្វើផែនការសកម្មភាពក្នុងការកំណត់អត្តសញ្ញាណជាមួយអ្នកពាក់ព័ន្ធ(នាយកសាលា គ្រូបន្ទុកថ្នាក់ មាតាបិតាសិស្ស គណៈកម្មការគ្រប់គ្រងសាលារៀន និងដៃគូអភិវឌ្ឍ)
- រៀបចំឧបករណ៍ និងសម្ភារៈសម្រាប់ធ្វើតេស្តក្នុងការកំណត់អត្តសញ្ញាណ
- កម្រងសំណួរតេស្ត
- ស្គរ បន្លឺសំឡេងតាមមាត់ (ផ្សឹសៗ) ទះដៃ ...



សំឡេង(PSSSS)



សំឡេងទះដៃ



សំឡេងទះស្គរ

កំណត់ចំណាំ៖ នៅពេលប្រើសម្ភារៈ តេស្តការស្តាប់ ក្នុងមួយលើកឱ្យឮសំឡេង ត្រឹមតែមួយដងៗ ឧទាហរណ៍ សំឡេងទះដៃ១ដងក្នុង១លើក។

## ជំហានទី២៖ ការរៀបចំបញ្ជីឈ្មោះកុមារ

- បញ្ជីឈ្មោះកុមារទាំងអស់ តាមកម្រិតថ្នាក់
- បញ្ជីឈ្មោះកុមារ ដែលសង្ស័យថាមានពិការភាព តាមរយៈគ្រូសង្កេត អាកប្បកិរិយារបស់កុមារ (កុមារអាចត្រូវបានសង្ស័យថាមានបញ្ហាស្តាប់)

- ផ្ញើលិខិតទៅមាតាបិតា ឬអ្នកអាណាព្យាបាលកុមារដើម្បីជូនដំណឹងអំពីដំណើរការនៃការកំណត់អត្តសញ្ញាណកុមារមានពិការភាព។

## ជំហានទី៣៖ កំណត់ទីតាំង

- ជ្រើសរើសបន្ទប់ ក្នុងបរិវេណសាលារៀន ដែលគ្មានសំឡេងរំខានដល់ការធ្វើតេស្ត។



## ជំហានទី៤៖ ពន្យល់ណែនាំកុមារ

- បង្កើតភាពស្និទ្ធស្នាល និងលើកទឹកចិត្តកុមារកុំឱ្យភ័យខ្លាច
- បង្ហាញឧបករណ៍សម្រាប់ធ្វើតេស្ត
- ចូរប្រើប្រាស់សម្ភារៈដែលមានក្នុងជំហានទី១
- អនុញ្ញាតឱ្យកុមារស្គាល់សម្ភារៈទាំងអស់ដែលត្រូវប្រើ
- ប្រាប់កុមារពីគោលបំណងនៃការធ្វើតេស្ត
- ណែនាំកុមារអំពីវិធីស្តាប់សំឡេងឱ្យបានច្បាស់ទៅតាមសំឡេងនីមួយៗដែលគ្រូយកមកអនុវត្ត ឧទាហរណ៍ ត្រូវស្តាប់ សូរសំឡេងស្គរ សូរសំឡេងទះដៃ ឬសំឡេងបន្លឺឡើងដោយមាត់ផ្ទាល់ សំឡេងផ្សិតៗ
- ណែនាំសិស្សអំពីវិធីឆ្លើយតប នៅពេលដែលគេបានឮសំឡេង
    - ប្រសិនបើគេបានឮសំឡេងពីត្រចៀកខាងឆ្វេង ត្រូវលើកដៃឆ្វេង
    - ប្រសិនបើគេបានឮសំឡេងពីត្រចៀកខាងស្តាំ ត្រូវលើកដៃស្តាំ
    - ប្រសិនបើគេបានឮសំឡេងពីត្រចៀកសងខាង ត្រូវលើកដៃទាំងពីរ

អនុញ្ញាតឱ្យកុមារបានអនុវត្តសាកល្បងផ្ទាល់ឱ្យបានច្បាស់លាស់ ដោយចាប់ផ្តើមពីដៃឆ្វេង បន្ទាប់មកដៃស្តាំ

## ជំហានទី៥៖ ដំណើរការតេស្ត

- គ្រូ ប្រើឧបករណ៍
    - ទះស្គរ
    - ទះដៃ
    - បន្លឺសំឡេង ផ្សឹសៗ PSSSS
- គ្រូអនុវត្តការធ្វើតេស្តផ្ទាល់ជាមួយកុមារចាប់ផ្ដើមពីដៃឆ្វេងទៅដៃស្ដាំ
- គ្រូដាក់ឧបករណ៍បង្កើតសំឡេងឱ្យស្មើនឹងកម្ពស់ត្រចៀករបស់កុមារ
- គ្រូបង្កើតសំឡេងនៃឧបករណ៍នីមួយៗ គឺចាប់ផ្ដើមពីសំឡេងតិចទៅសំឡេងខ្លាំង ដោយផ្អែកតាមកម្រិតលេកសំឡេងនៃត្រចៀករបស់កុមារ
- កុមារឆ្លើយតបនៅពេលដែលគេបានឮសំឡេង





**ការណែនាំកុមារមុនពេលធ្វើតេស្តស្ដាប់**

- លើកទី១៖
    - គ្រូទះដៃ ឬទះស្គរ ឬសំឡេង ផ្សឹសៗ PSSSS ពីចំហៀង ត្រចៀកខាងឆ្វេង របស់កុមារចម្ងាយប្រហែល១ម៉ែត្រ
    - ឱ្យកុមារលើកដៃឆ្វេង ប្រសិនបើគេបានឮពីត្រចៀកខាងឆ្វេង
- លើកទី២៖
    - គ្រូទះដៃ ឬទះស្គរ ឬសំឡេង ផ្សឹសៗ PSSSS ពីចំហៀង ត្រចៀកខាងស្ដាំ របស់កុមារ ចម្ងាយប្រហែល ១ម៉ែត្រ
    - ឱ្យកុមារលើកដៃស្ដាំ ប្រសិនបើគេបានឮពីត្រចៀកខាងស្ដាំ

- លើកទី៣៖
    - គ្រូទះដៃ ឬទះស្គរ ឬសំឡេង ផ្សីសៗ PSSSS ដោយឈរចំពីក្រោយកុមារ ចម្ងាយប្រហែល ១ម៉ែត្រ
    - ឱ្យកុមារលើកដៃឆ្វេង ប្រសិនបើគេបានឮពីត្រចៀកខាងឆ្វេង
    - ឱ្យកុមារលើកដៃស្តាំ ប្រសិនបើគេបានឮពីត្រចៀកខាងស្តាំ

**ចំណាំ៖**

- គ្រូមិនត្រូវប្រាប់កុមារនោះទេ នៅពេលដែលប្តូរពីការអនុវត្តត្រចៀកខាងឆ្វេង ឬខាងស្តាំ
- កុមារអាចលើកដៃទាំងពីរ នៅពេលគេបានឮសំឡេងពីត្រចៀកទាំងសងខាង
- ប្រសិនបើកុមារមិនឮសំឡេង ឬមិនទាន់លើកដៃ
- ប្រសិនបើកុមារមិនឮសំឡេង ឬមិនទាន់លើកដៃពីផ្នែកណាមួយ គ្រូត្រូវធ្វើចំនួន ២-៣ ដង




ធ្វើតេស្តការស្តាប់ដោយទះដៃ ធ្វើតេស្តការស្តាប់ដោយសំឡេងហ្សីសៗ និងធ្វើតេស្តការស្តាប់ដោយសំឡេងស្គរ

- គ្រូត្រូវគូសសញ្ញា(√)នៅក្នុងជួរឈរ "បាទ/ចាស ឬទេ" ក្នុងតារាងកម្រងសំណួរខាងក្រោម
- គ្រូបំពេញកម្រងសំណួរតេស្តកុមារដែលមានបញ្ហាស្តាប់

កម្រងសំណួរ សម្រាប់កំណត់អត្តសញ្ញាណ កុមារមានបញ្ហាស្តាប់

| ល.រ | សំណួរ | បាទ/ចាស | ទេ |
|---|---|---|---|
| ១ | តើកុមារពិបាកស្តាប់ឬទេ នៅពេលយើងនិយាយពីក្រោយខ្នងគេ ? | | |
| ២ | តើកុមារមានផ្ទៀងត្រចៀកស្តាប់ ដែរឬទេ ? | | |
| ៣ | តើកុមារនិយាយខ្លាំងៗពេក ដែរឬទេ ? | | |
| ៤ | តើកុមារនិយាយតិចពេក ឬទេ ? | | |
| ៥ | តើកុមារអាចយល់បានដែរឬទេបន្ទាប់ពីអ្នកនិយាយសាឡើងវិញមួយឬពីរដង ? | | |
| ៦ | តើកុមារឆ្លើយមិនចំនឹងសំណួរ ដែរឬទេ ? | | |
| កំណត់សម្គាល់៖ ប្រសិនបើមានចម្លើយ "បាទ/ចាស" ចំនួនបី នោះកុមារមានបញ្ហាស្តាប់ | | | |

## ជំហានទី៦៖ កំណត់ត្រាលទ្ធផល

- ចូរប្រើតារាងទី ១ ក្នុងឧបសម្ព័ន្ធ
- យោងតាមលទ្ធផល នៃការបំពេញកម្រងសំណួរកំណត់អត្តសញ្ញាណដែលបានរកឃើញ និងសង្ស័យថាកុមារមានបញ្ហាស្តាប់
- ស្រង់ឈ្មោះកុមារ បញ្ជីឈ្មោះកុមារដែលសង្ស័យថា មានបញ្ហាស្តាប់

## ជំហានទី៧៖ ការបញ្ជូនទៅរកសេវា

- ចូរប្រើតារាងទី ២ ក្នុងឧបសម្ព័ន្ធ
- បញ្ជូនកុមារដែលសង្ស័យថាមានបញ្ហាស្តាប់ទៅរកអ្នកឯកទេសផ្នែកត្រចៀកដែលនៅជិតបំផុត ឬតាមអាសយដ្ឋានក្នុងតារាងឧបសម្ព័ន្ធទី១។
- ករណីរកឃើញកុមារសង្ស័យថាមានបញ្ហាត្រូវជូនដំណឹងទៅមាតាបិតា ឬអ្នកអាណាព្យាបាល ដើម្បីបញ្ជូនទៅរកសេវាគាំទ្រសមស្របនានា
- ក្នុងករណីគ្រូពេទ្យឯកទេសបានរកឃើញថាកុមារមានបញ្ហាស្តាប់ អ្នកអាណាព្យាបាលត្រូវបញ្ជូនកុមារទៅរកសេវាគាំទ្រសមស្របនៅតាមមន្ទីរពេទ្យ មជ្ឈមណ្ឌលស្តារ ឬអង្គការនានាតាមវេជ្ជបញ្ជា។

## ជំហានទី៨៖ ពិនិត្យតាមដាន

- ចូរប្រើតារាងទី៣ ក្នុងឧបសម្ព័ន្ធ
- គ្រូត្រូវស្រង់ឈ្មោះកុមារដាក់ក្នុងបញ្ជីពិនិត្យតាមដាន
- គ្រូកត់ត្រាអំពីការវិវឌ្ឍនៃការស្តាប់
- សាលារៀន មាតាបិតា អ្នកអាណាព្យាបាលត្រូវធ្វើការតាមដាន និងកត់ត្រាការវិវឌ្ឍនៃការស្តាប់ និងការរៀនសូត្ររបស់កុមារ
    - តើកុមារបានទៅរកសេវាដែរឬទេ?
    - តើកុមារបានទទួលសេវាគាំទ្រ ឬឧបករណ៍ជំនួយអ្វីខ្លះ?
    - តើកុមារមានការប្រែប្រួលឥរិយាបថរៀនសូត្រអ្វីខ្លះ?



# ការអនុវត្ត ការកំណត់អត្តសញ្ញាណកុមារ
# មានបញ្ហានិយាយ

## វត្ថុបំណង៖

- ពង្រឹងសមត្ថភាពគ្រូ ក្នុងការកំណត់អត្តសញ្ញាណកុមារមានបញ្ហានិយាយ
- ផ្តល់ព័ត៌មានដល់អ្នកអាណាព្យាបាល និងស្វែងរកសេវាគាំទ្រសមស្របបានទាន់ពេលវេលា
- បង្កើន និងពង្រឹងយន្តការនៃការកំណត់អត្តសញ្ញាណកុមារមានបញ្ហានិយាយ នៅតាមសាលារៀន ប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព។

## ជំហានក្នុងការកំណត់អត្តសញ្ញាណ កុមារមានបញ្ហានិយាយ

## ជំហានទី១៖ ការរៀបចំផែនការ

- ជួបពិភាក្សាជាមួយអ្នកពាក់ព័ន្ធ
- កំណត់ទីតាំងនិង ពេលវេលា
- រៀបចំឧបករណ៍ និងសម្ភារៈ
- ឧបករណ៍តេស្តលើបញ្ហានិយាយរបស់កុមារ
    - ❖ បណ្ណរូបភាព ឬវត្ថុពិតជាក់ស្តែង
    - ❖ លិខិតជូនដំណឹងទៅអ្នកអាណាព្យាបាល
    - ❖ ឧបករណ៍ពិនិត្យតាមដាន និងវាយតម្លៃ

## ជំហានទី២៖ ការរៀបចំសម្ភារៈ

- ប្រមូលបញ្ជីឈ្មោះសិស្សទាំងអស់
- បញ្ជីឈ្មោះសិស្សដែលសង្ស័យថាមានបញ្ហា(តារាងស្ថិតិកុមារមានពិការភាព)
- រៀបចំសម្ភារៈសម្រាប់ធ្វើតេស្ត រូបភាព វត្ថុផ្សេងៗ ដោយប្រើរូបភាពងាយៗ
- ធ្វើការសង្កេត និងស្តាប់ទៅលើការបញ្ចេញសូរសំឡេងរបស់កុមារដែលសង្ស័យថាមានបញ្ហានិយាយ

## ជំហានទី៣៖ ការកំណត់ទីតាំង

- រៀបចំទីកន្លែងសម្រាប់សម្ភាសន៍ និងធ្វើតេស្តកុមារឱ្យបានសមរម្យ

## ជំហាននទី៤៖ ការណែនាំ និងអនុវត្ត

- សំណេះសំណាលជាមួយកុមារ ដើម្បីបង្កើនភាពស្និទ្ធស្នាលជាមួយកុមារ
- ប្រាប់អំពីគោលបំណង នៃការធ្វើតេស្ត
- បង្ហាញសម្ភារៈមួយចំនួនដែលសម្រាប់ធ្វើតេស្តបញ្ហានិយាយ

## ជំហានទី៥៖ ដំណើរការនៃការធ្វើតេស្ត

### ការណែនាំអំពីដំណើរការ៖

- អ្នកចូលរួម៖ កុមារផ្ទាល់ មាតាបិតា ឬអ្នកអាណាព្យាបាល ឬគ្រូប្រចាំថ្នាក់
- ប្រាប់ពីគោលបំណងនៃការធ្វើតេស្ត (នៅក្នុងជំហានទី៤)
- ប្រាប់ពីរបៀបឆ្លើយតប ទៅនឹងសំណួរតេស្ត
- ធ្វើតេស្ត ដោយការនិយាយ ឱ្យកុមារឆ្លើយតប
- ធ្វើតេស្ត ដោយប្រើចលនាបបូរមាត់ ឱ្យកុមារសង្កេត និងឆ្លើយតប
- ឱ្យកុមារ អនុវត្តការនិយាយដោយផ្ទាល់ ឬសង្កេតសកម្មភាព ពេលនិយាយ។

### ការអនុវត្តការធ្វើតេស្ត៖

- គ្រូប្រើកម្រងសំណួរ ឧបករណ៍តេស្ត លើបញ្ហានិយាយរបស់កុមារ
    - ❖ គ្រូអនុវត្តការធ្វើតេស្តជាមួយកុមារ ដោយផ្ទាល់
    - ❖ ស្តាប់ ការនិយាយ និងការបញ្ចេញសំឡេងរបស់កុមារ
    - ❖ សង្កេត
    - ❖ សួរឪពុកឬម្តាយ ប្រសិនបើកុមារ មិនអាចឆ្លើយតបបាន
    - ❖ គូសចម្លើយ "បាទ/ចាស" ក្នុងកម្រងសំណួរ
- គ្រូប្រើកម្រងសំណួរ ជំនួយបន្ថែម សម្រាប់ធ្វើតេស្តកុមារ មានបញ្ហានិយាយ តាមកម្រិតអាយុ២-៥ឆ្នាំ
    - ❖ គ្រូប្រើប្រាស់រូបភាព ឬវត្ថុចំនួន៣ ទៅ៥ ទៅតាមកម្រិតអាយុរបស់កុមារ
    - ❖ គ្រូលើករូបភាពបង្ហាញ ឬវត្ថុមួយចំនួន ហើយសួរសំណួរ ។
- បូកសរុបលទ្ធផល នៃការធ្វើតេស្តរបស់កុមារម្នាក់ៗ

កំណត់សម្គាល់៖ ដំបូងគ្រូត្រូវសង្កេតកុមារក្នុងថ្នាក់ ប្រសិនបើកុមារ និយាយត្រដិត និយាយក្ងួរ ជំឡាន់ ឬដាក់រដុប នោះកុមារ មានបញ្ហានិយាយ។





កម្រងសំណួរ ឧបករណ៍តេស្តលើបញ្ហានិយាយរបស់កុមារ

| ល.រ | សំណួរ | បាទ/ចាស | ទេ |
|---|---|---|---|
| ១ | តើកុមារមានការលំបាកនិយាយពាក្យ និងមានបាត់បង់ សូរសំឡេងមួយចំនួន នៅពេលនិយាយ ដែរឬទេ ? | | |
| ២ | តើកុមារនិយាយត្រដិត និយាយក្ងួរ ឬជំឡាន់ រដាក់រដុប ដែរឬទេ ? | | |
| ៣ | តើកុមារមានចង្អុល ឬប្រើភាសាសញ្ញា ជំនួសឱ្យការនិយាយ ដែរឬទេ ? | | |
| ៤ | តើកុមារ មិនអាចប្រើប្រាស់ពាក្យ (២-៣ព្យាង្គ) ឬឃ្លា បានច្រើនជាង២ ដែរឬទេ ? កំណត់កម្រិតអាយុ៣ឆ្នាំ ៤ឆ្នាំ ៦ឆ្នាំ ឱ្យស្គាល់ប៉ុន្មានពាក្យ | | |
| កំណត់សម្គាល់៖ ប្រសិនបើមានចម្លើយណាមួយ ឆ្លើយថា "បាទ/ចាស" នោះបញ្ជាក់ថា កុមារ អាចមានបញ្ហានិយាយ។ | | | |

កម្រងសំណួរ ជំនួយបន្ថែម សម្រាប់ធ្វើតេស្តកុមារ មានបញ្ហានិយាយ តាមកម្រិតអាយុ២-៥ឆ្នាំ

| អាយុ | កម្រងសំណួរ | ចម្លើយ | |
|---|---|---|---|
| | | បាទ/ចាស | ទេ |
| ២ឆ្នាំ | ១. តើកុមារអាចនិយាយ ពីរពាក្យជាប់គ្នាដែរឬទេ ? | | |
| | ២. តើកុមារអាចចង្អុល និងស្គាល់ វត្ថុឬរូបភាព ដែរឬទេ ? | | |
| ៣ឆ្នាំ | ៣. តើកុមារអាចនិយាយឃ្លាប្រយោគខ្លីៗចាប់ពីបួនឬប្រាំពាក្យជាប់គ្នាបានដែរឬទេ ? (និយាយពាក្យត្រឹមត្រូវបាន៥០%) | | |
| ៤. តើកុមារអាចហៅឈ្មោះសត្វ វត្ថុដែលគេស្គាល់បាន ដែរឬទេ ? | | | |
| | ៥. តើកុមារអាចប្រាប់ឈ្មោះ ភេទរបស់ខ្លួនបាន ដែរឬទេ ? | | |
| ៤ឆ្នាំ | ៦. តើកុមារអាចនិយាយប្រាប់ពណ៌យ៉ាងតិចពីរបាន ដែរឬទេ ? | | |
| | ៧. តើកុមារអាចប្រាប់ពីរូបរាងឬ ទ្រង់ទ្រាយវត្ថុបាន ដែរឬទេ ? (ឧទា. រាងមូល ជ្រុង វែង ខ្លី ...) | | |
| | ៨. តើកុមារអាចប្រាប់ពីមុខងារនៃវត្ថុ ពីរឬច្រើនបាន ដែរឬទេ ? (ឧទា.តើស្លាបព្រាប្រើសម្រាប់ធ្វើអ្វី ? ) | | |
| | ៩. តើកុមារអាចប្រាប់ពីទីតាំងនៃវត្ថុមួយបាន ដែរឬទេ ? (ឧទា. ខាងលើ ក្រោម ក្នុង ក្រៅ មុខ ឬក្រោយ) | | |

| | | | |
|---|---|---|---|
| ៥ឆ្នាំ ឡើង | ១១. តើកុមារអាចនិយាយបានច្រើនពាក្យ ឬរៀបរាប់ពីអ្វីដែលខ្លួនដឹងបានដែរឬទេ? | | |
| | ១២. តើកុមារអាចនិយាយរឿងឡើងវិញបាន ដែរឬទេ? | | |
| | ១៣. តើកុមារប្រាប់បានពីភាពខុសគ្នា នៃសត្វ ឬវត្ថុ បានដែរឬទេ?<br>(ឧទា. សត្វដំរីធំ ជាងសត្វកណ្ដុរ) | | |

កំណត់សម្គាល់៖ ប្រសិនបើ មានចម្លើយ "ទេ" ចំនួនពីរ ឬច្រើនជាងពីរ តាមកម្រិតអាយុ នោះកុមារ មានបញ្ហានិយាយ។

## ជំហានទី៦៖ របាយការណ៍លទ្ធផលតេស្ត

- ចូរប្រើតារាងទី១ ក្នុងឧបសម្ពន្ធ
- យោងតាមលទ្ធផលនៃការបំពេញកម្រងសំណួរកំណត់អត្តសញ្ញាណដែលបានរកឃើញ និងសង្ស័យថា កុមារមានបញ្ហានិយាយ
- ស្រង់ឈ្មោះកុមារ និងធ្វើបញ្ជីឈ្មោះកុមារដែលសង្ស័យថា មានបញ្ហានិយាយ

## ជំហានទី៧៖ ការជូនដំណឹង និងការបញ្ជូន

- ចូរប្រើតារាងទី២ ក្នុងឧបសម្ពន្ធ
- ករណីរកឃើញកុមារសង្ស័យថាមានបញ្ហានិយាយ ត្រូវជូនដំណឹងទៅមាតាបិតា ឬអ្នកអាណាព្យាបាលរបស់ពួកគេ ដើម្បីបញ្ជូនទៅរកសេវាស្តារបញ្ហានិយាយ
- ចូរមើលគំរូលិខិតជូនដំណឹង ក្នុងឧបសម្ពន្ធ
- នាយកសាលា ឬគ្រូត្រូវណាត់ជាមួយអ្នកផ្តល់សេវា ដើម្បីបញ្ជូនកុមារទៅរកសេវា
- មាតាបិតា ឬអ្នកអាណាព្យាបាល សហការជាមួយសាលា បញ្ជូនកុមារទៅរកសេវា និងតាមដានការបញ្ជូន

## ជំហានទី៨៖ ឧបករណ៍ពិនិត្យតាមដាន និងវាយតម្លៃ

- ចូរប្រើតារាងទី៣ ក្នុងឧបសម្ពន្ធ
- មាតាបិតា ឬអ្នកអាណាព្យាបាល សហការជាមួយសាលារៀន តាមដានសុខភាពកុមារ
- មាតាបិតា ឬអ្នកអាណាព្យាបាល សហការជាមួយសាលារៀន ដើម្បីបញ្ជូនកុមារទៅរកសេវាជាបន្តបន្ទាប់ តាមដំបូន្មានរបស់អ្នកផ្តល់សេវា

# ការអនុវត្ត ការកំណត់អត្តសញ្ញាណ កុមារ មានបញ្ហាសតិបញ្ញា

## វត្ថុបំណង៖

- ពង្រឹងសមត្ថភាពរបស់គ្រូ ក្នុងការកំណត់អត្តសញ្ញាណកុមារមានបញ្ហាសតិបញ្ញា
- ផ្ដល់ព័ត៌មានដល់អ្នកអាណាព្យាបាល និងស្វែងរកសេវាគាំទ្រសមស្រប និងទាន់ពេលវេលា
- បង្កើន និងពង្រឹងយន្តការនៃការកំណត់អត្តសញ្ញាណកុមារមានបញ្ហាសតិបញ្ញា នៅតាមសាលារៀន ប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព។

## ជំហានក្នុងការកំណត់អត្តសញ្ញាណកុមារ មានបញ្ហាសតបញ្ញា

## ជំហានទី១៖ ការរៀបចំសម្ភារៈ

- ប្រជុំពិភាក្សានិងធ្វើផែនការសកម្មភាពក្នុងការកំណត់អត្តសញ្ញាណ ជាមួយអ្នកពាក់ព័ន្ធ(នាយកសាលា គ្រូទទួលបន្ទុកថ្នាក់ មាតាបិតាសិស្ស គណៈកម្មការគ្រប់គ្រងសាលារៀន និងដៃគូអភិវឌ្ឍ)
- រៀបចំឧបករណ៍ និងសម្ភារៈសម្រាប់ធ្វើតេស្តក្នុងការកំណត់អត្តសញ្ញាណ
    - ❖ មានបញ្ជាក់នៅក្នុងជំហានទី៥

## ជំហានទី២៖ ការរៀបចំបញ្ជីឈ្មោះកុមារ

- បញ្ជីឈ្មោះកុមារទាំងអស់ តាមកម្រិតថ្នាក់
- បញ្ជីឈ្មោះកុមារ ដែលសង្ស័យថាមានបញ្ហាពិការភាព តាមរយៈគ្រូសង្កេត អាកប្បកិរិយារបស់កុមារ (កុមារអាចត្រូវបានសង្ស័យថា មានបញ្ហាស្ដាប់ បញ្ហាមើល បញ្ហាសតិបញ្ញា បញ្ហាចលនា និងបញ្ហានិយាយ)
- រៀបចំ និងផ្ញើលិខិតជូនដំណឹង ទៅកាន់អ្នកអាណាព្យាបាល។

## ជំហានទី៣៖ ការកំណត់ទីតាំង

- ជ្រើសរើសបន្ទប់ក្នុងបរិវេណសាលារៀនដែលគ្មានសំឡេងរំខានដល់ដំណើរការនៃការធ្វើតេស្ត
- រៀបចំទីកន្លែងដែលសមស្រប និងគ្មានការរំខាន។

## ជំហានទី៤៖ ការពន្យល់ និងការណែនាំ

- បង្កើនភាពស្និទ្ធស្នាល និងលើកទឹកចិត្តកុមារ កុំឱ្យភ័យខ្លាច
- បង្ហាញឧបករណ៍សម្រាប់ការធ្វើតេស្ត
- បង្ហាញពីសម្ភារៈ និងឧបករណ៍សម្រាប់ការធ្វើតេស្ត ក្នុងជំហានទី១
- ពន្យល់ណែនាំអ្នកអាណាព្យាបាលនិងកុមារ អំពីគោលបំណង និងវិធីសាស្ត្រនៃការធ្វើតេស្ត

## ជំហានទី៥៖ ដំណើរការនៃការធ្វើតេស្ត

- សម្ភាសន៍ជាមួយអ្នកអាណាព្យាបាលអំពីប្រវត្តិ និងបញ្ហាផ្សេងៗរបស់កុមារ (ប្រើប្រាស់កម្រងសំណួរខាងក្រោម)
- សង្កេតកុមារដោយប្រយោល
- អាចសង្កេតនៅពេលកុមារលេង និងការធ្វើសកម្មភាពផ្សេងៗជាមួយអ្នកដទៃ។

## ការធ្វើតេស្តកុមារផ្ទាល់

កត់សម្គាល់អំពីសកម្មភាព អាកប្បកិរិយា ការយល់ដឹង និងការទំនាក់ទំនងផ្សេងៗរបស់កុមារ ដើម្បីស្វែងរកពីភាពមិនប្រក្រតីដូចជា៖ លេងម្នាក់ឯង មិនចែករំលែក មិនចូលរួម វាយក្មេងដទៃ...។

- អង្គុយទល់មុខកុមារ កម្ពស់ស្មើគ្នា ដោយមានសម្ភារៈសម្រាប់អនុវត្តផ្ទាល់ ឧទាហរណ៍៖ វត្ថុពិត ឬរូបភាព
- កត់ត្រារាល់ភាពមិនប្រក្រតីនានា ហើយដាក់ចូលក្នុងកម្រងសំណួរ។

កម្រងសំណួរ កំណត់អត្តសញ្ញាណ កុមារមានបញ្ហាសតិបញ្ញា

| ល.រ | សំណួរ | បាទ ឬ ចាស | ទេ |
|---|---|---|---|
| | បើប្រៀបធៀប នឹងកុមារដទៃ ដែលអាយុប្រហាក់ប្រហែលគ្នា៖ | | |
| ១ | តើកុមារហាក់ដូចជា មិនអាចយល់ឬចង្អុលប្រាប់ផ្នែកផ្សេងៗនៃរាងកាយ? | | |
| ២ | តើកុមារពិបាក ធ្វើសកម្មភាពដែរឬទេ? (ដោះនិងស្លៀកពាក់ខោ អាវ ខាងខុសឬខាងត្រូវបិទឡេវអាវបានត្រឹមត្រូវនិងពាក់ស្បែកជើងត្រូវឆ្វេង ស្តាំ | | |
| ៣ | តើកុមារធ្លាប់ប្រកាច់ ឬបាត់បង់ស្មារតី ម្តងម្កាល ដែរឬទេ? | | |
| ៤ | តើកុមារពិបាកក្នុងការផ្លាស់ប្តូរសកម្មភាពប្រចាំថ្ងៃ ដែរឬទេ? | | |
| ៥ | តើកុមារមានអាប្បកិរិយាខុសប្លែក ពីកុមារដទៃ ដែរឬទេ? មានដូចជាការផ្ចង់អារម្មណ៍លើកិច្ចការ ការរំខានអ្នកដទៃ រឹងរូស ឬការលេង ការផ្ចង់អារម្មណ៍ជាមួយវត្ថុតែមួយ៉ាង... | | |
| ៦ | តើកុមារចូលចិត្ត លេងតែម្នាក់ឯង ឬលេងមានលក្ខណៈខុសប្លែកពីកុមារដទៃដែរឬទេ? | | |
| ៨ | តើកុមារពិបាកចងចាំដែរឬទេ? ឧទាហរណ៍៖ ប្រាប់កុមារថា គេនឹងត្រូវនិយាយពាក្យចំនួន៣-៥ តាមលំដាប់ដែលគ្រូបាននិយាយ "គោ ឆ្មា មាន់ ក្របី ទា" កុមារនិយាយពាក្យ តាមលំដាប់លំដោយ។ | | |

| |
|---|
| កំណត់សម្គាល់៖ ប្រសិនបើមានចំនួន បាទ ចំនួន៤ នោះកុមារអាចមានបញ្ហាសតិបញ្ញា។ |

## ជំហានទី៦៖ របាយការណ៍លទ្ធផលនៃការធ្វើតេស្ត

- ចូរប្រើតារាងទី១ ក្នុងឧបសម្ពន្ធ

## ជំហានទី៧៖ ការបញ្ជូន

- ករណីរកឃើញកុមារសង្ស័យថាមានបញ្ហាសតិបញ្ញា ត្រូវជូនដំណឹងទៅឪពុកម្ដាយ ឬអ្នកអាណាព្យាបាលរបស់ពួកគេ ដើម្បីបញ្ជូនទៅរកបំណិនឯកទេស
- ក្នុងករណីបំណិនឯកទេសបានកំណត់ពីកម្រិតនៃបញ្ហាសតិបញ្ញារបស់កុមារ ត្រូវធ្វើការបញ្ជូនទៅរកសេវាគាំទ្រសមស្របផ្សេងៗនៅតាមមន្ទីរពេទ្យ មជ្ឈមណ្ឌលស្ដារលទ្ធភាពពលកម្មឬអង្គការឯកទេសផ្ដល់សេវា
- ចូរប្រើតារាងទី២ ក្នុងឧបសម្ពន្ធ

## ជំហានទី៨៖ ការពិនិត្យតាមដាន

- គ្រូត្រូវស្រង់ឈ្មោះកុមារដែលមានបញ្ហាសតិបញ្ញាក្នុងបញ្ជីពិនិត្យតាមដាន
- គ្រូកត់ត្រាអំពីការវិវឌ្ឍសតិបញ្ញារបស់កុមារ
- សាលារៀន មាតាបិតា ឬអ្នកអាណាព្យាបាលត្រូវធ្វើការតាមដានការវិវឌ្ឍរបស់កុមារជាប្រចាំ។
    - ❖ តើកុមារបានទៅរកសេវាសតិបញ្ញាដែរឬទេ ?
    - ❖ តើកុមារបានទទួលសេវាស្ដារ សតិបញ្ញាដែរឬទេ ?

❖ តើកុមារបានទទួលការគាំទ្រអ្វីខ្លះ ពីសេវាស្ដារសតិបញ្ញា ?




សកម្មភាព ជំនួយបន្ថែម សម្រាប់ការធ្វើតេស្ត កុមារមានបញ្ហាសតិបញ្ញាកំណត់សម្គាល់ ប្រភេទផ្សេងៗនៃលេងរបស់កុមារ

# ការវាយតម្លៃ បញ្ហាសតបញ្ញា ត្រូវផ្ដោតលើបំណិននីមួយៗ ដូចខាងក្រោម៖

## ១. បំណិនទំនាក់ទំនងសង្គម៖

វត្ថុបំណង៖ ស្វែងយល់ពីកម្រិតទំនាក់ទំនងរបស់កុមារ។

ឧបករណ៍សម្រាប់ការធ្វើតេស្ត៖ ប្រើប្រាស់ឧបករណ៍តេស្ត ឬសកម្មភាពផ្សេងៗដែលអាចឱ្យកុមារលេងជាមួយគ្នាដើម្បីដឹងថា តើកុមារអាចលេងជាមួយកុមារដទៃតាមរបៀបណា ? ចេះចែករំលែកឬស្នើសុំរបស់អ្វីមួយពីអ្នកដទៃដែរឬទេ ? ចេះសុំទោសនៅពេលដែលធ្វើខុសដែរឬទេ ? ឬចេះយល់ពីអារម្មណ៍របស់អ្នកដទៃដែរឬទេ ?។




ប្រើប្រាស់សម្ភារៈផ្សេងៗដើម្បីឱ្យកុមារលេងជាមួយគ្នា



បង្កើតសកម្មភាពដើម្បីឱ្យកុមារលេងជាមួយគ្នា

## ២. បំណិននៃការយល់ដឹង៖

វត្ថុបំណង៖ ស្វែងយល់ពីការយល់ដឹងរបស់កុមារទៅលើ រូបរាង ពណ៌ រូបភាព និងទំនាក់ទំនងពីវត្ថុមួយទៅវត្ថុមួយ។

ឧបករណ៍សម្រាប់ធ្វើតេស្ត៖ ប្រើប្រាស់ឧបករណ៍តេស្ត ឬសកម្មភាពផ្សេងៗ ដែលអាចឱ្យកុមារ ផាត់ពណ៌  គូររូប ប្រាប់ឈ្មោះវត្ថុអ្វីមួយ ឬរូបរាងនៃវត្ថុនោះ។



យល់ដឹងពីពណ៌



យល់ដឹងពីវត្ថុ



យល់ដឹងពីរូបរាងផ្សេងៗ

### ៣. បំណិនជួយខ្លួនឯង៖

វត្ថុបំណង៖ ស្វែងយល់ពីបំណិនថែទាំខ្លួន និងការធ្វើសកម្មភាពប្រចាំថ្ងៃរបស់កុមារដោយខ្លួនឯង។

ឧបករណ៍សម្រាប់ការធ្វើតេស្ត៖ ប្រើប្រាស់ឧបករណ៍ ឬសកម្មភាពផ្សេងៗ ដែលអាចតេស្តកុមារក្នុងបំណិនជួយខ្លួនឯង ដូចជា៖ ងូតទឹក ស្លៀកពាក់ ដុសធ្មេញ ញ៉ាំអាហារ ចូលបន្ទប់ទឹក...។







ប្រើឧបករណ៍ ឬសកម្មភាពដើម្បីឱ្យកុមារប្រើចលនាដៃ ក្នុងការស្លៀកសម្លៀកបំពាក់។

### ៤. បំណិនចលនា

វត្ថុបំណង៖ ស្វែងយល់ពីការធ្វើចលនាធំនិងចលនាតូច លើផ្នែកនៃរាងកាយ បញ្ញាស្មារតី ជាពិសេសលើញាណដឹង ការយល់ដឹងពីចលនាបម្លាស់ទី និងការទប់លំនឹងរបស់កុមារ។

### ៤.១. ចលនាធំ៖

ឧបករណ៍សម្រាប់ធ្វើតេស្ត៖ ប្រើប្រាស់ឧបករណ៍ ឬសកម្មភាពផ្សេងៗ ដែលអាចធ្វើតេស្តកុមារក្នុងការធ្វើ ចលនាធំ (ដេក ដើរ ឈរ អង្គុយ) ដើម្បីធ្វើតេស្តទៅលើញាណដឹង និងការយល់ដឹងពីបម្លាស់ទីនៃការធ្វើចលនាដោយញាណ និងការទប់លំនឹងរបស់កុមារ។











ប្រើប្រាស់ឧបករណ៍ឬសកម្មភាពផ្សេងៗដើម្បីការយល់ដឹងពីបម្លាស់ទីនៃចលនាដោយញាណ

ប្រើប្រាស់ឧបករណ៍ឬសកម្មភាពផ្សេងៗ ដើម្បីឱ្យកុមារឈរ អង្គុយ រួចផ្ចង់អារម្មណ៍ បោះបាល់ឬឧបករណ៍ ទៅកាន់គោលដៅអ្វីមួយ

ប្រើប្រាស់ឧបករណ៍ឬសកម្មភាពផ្សេងៗដើម្បីការយល់ដឹងពីបម្លាស់ទីនៃចលនាដោយញាណ

## ៤.២. ចលនាតូច

ឧបករណ៍ប្រើសម្រាប់ការធ្វើតេស្ត៖ ប្រើប្រាស់ឧបករណ៍ ឬសកម្មភាពផ្សេងៗ ដែលអាចតេស្តកុមារក្នុងការធ្វើចលនាតូច( ចាប់កាន់ ) ដើម្បីធ្វើតេស្តទៅលើញាណដឹង និងការយល់ដឹងពីបម្លាស់ទីនៃចលនាដោយញាណ និងការទប់លំនឹងរបស់កុមារ។



ប្រើប្រាស់ឧបករណ៍ ផ្សេងៗ ដើម្បីតេស្តញាណដឹងកុមារ



ប្រើប្រាស់ឧបករណ៍ឬ សកម្មភាពផ្សេងៗដើម្បី ឱ្យកុមារប្រើដៃ ចាប់កាន់ឬច្របាច់



ប្រើប្រាស់ឧបករណ៍ផ្សេងៗ ដើម្បីតេស្តការចាប់កាន់ និងផ្ទង់អារម្មណ៍របស់កុមារ



ប្រើប្រាស់ឧបករណ៍ឬសកម្មភាពផ្សេងៗដើម្បីតេស្តការចាប់កាន់ និងផ្ទង់អារម្មណ៍ និងគ្រប់គ្រងចលនាដៃ និងភ្នែករបស់កុមារ

កំណត់សម្គាល់៖ ការវាយតម្លៃបញ្ហាសតិបញ្ញារបស់កុមារ ត្រូវផ្តោតទៅលើកម្រិតនៃការយល់ដឹង តាមអាយុជាក់ស្តែង។

# ការអនុវត្ត ការកំណត់អត្តសញ្ញាណ កុមារ មានបញ្ហាមើល

## វត្ថុបំណង៖

- ពង្រឹងសមត្ថភាពគ្រូ ក្នុងការកំណត់អត្តសញ្ញាណបឋម ដើម្បីស្វែងរកកុមារ មានបញ្ហាមើល
- ផ្តល់ព័ត៌មាន និងស្វែងរកសេវាគាំទ្រ សមស្រប និងទាន់ពេលវេលា
- បង្កើន និងពង្រឹងយន្តការ វាស់គំហើញរបស់កុមារ នៅតាមសាលារៀន ប្រកបដោយគុណភាព និងមាននិរន្តរភាព។

## ជំហាន ក្នុងការកំណត់អត្តសញ្ញាណកុមារ មានបញ្ហាមើល

## ជំហានទី១៖ ការរៀបចំសម្ភារៈ និងឯកសារ

### ក. សម្ភារៈ

- តារាងលាផាត (Lea Symbols Chart) ឬប្រើតារាងអ៊ីផាត (E-Chart)
- ដៃបាំងភ្នែក ឬវ៉ែនតាបាំងភ្នែក ឬបាំងភ្នែក
- ម៉ែត្រសម្រាប់វាស់ចម្ងាយ










## ខ. ឯកសារ

១. កម្រងសំណួរ កំណត់អត្តសញ្ញាណ ដើម្បីស្វែងរកកុមារ មានបញ្ហាមើល

២. តារាងកំណត់ត្រា លទ្ធផលវាស់គំហើញ

| ល.រ | ឈ្មោះកុមារ | ភេទ | អាយុ | ភ្នែកស្តាំ | | ភ្នែកឆ្វេង | | បញ្ជូន | លេខទូរសព្ទ អ្នកអាណាព្យាបាល |
|---|---|---|---|---|---|---|---|---|---|
| | | | | ៦/៦០ ឬ ៣/៣០ | ៦/១២ ឬ ៣/៦ | ៦/៦០ ឬ ៣/៣០ | ៦/១២ ឬ ៣/៦ | | |
| ១ | | | | ☐ ខ្សោយគំហើញ | ☐ ធម្មតា | ☐ ខ្សោយគំហើញ | ☐ ធម្មតា | | |
| ២ | | | | ☐ ខ្សោយគំហើញ | ☐ ធម្មតា | ☐ ខ្សោយគំហើញ | ☐ ធម្មតា | | |
| ៣ | | | | ☐ ខ្សោយគំហើញ | ☐ ធម្មតា | ☐ ខ្សោយគំហើញ | ☐ ធម្មតា | | |

## ជំហានទី២៖ រៀបចំបញ្ជីឈ្មោះកុមារ

- រៀបចំបញ្ជីឈ្មោះកុមារទាំងអស់ តាមកម្រិតថ្នាក់
- រៀបចំបញ្ជីឈ្មោះកុមារ ដែលសង្ស័យថា មានបញ្ហាមើល តាមរយៈការសង្កេតអាកប្បកិរិយារបស់កុមារ
- ផ្ញើលិខិត ទៅមាតាបិតា ឬអ្នកអាណាព្យាបាលកុមារ អំពីការកំណត់អត្តសញ្ញាណកុមារមានពិការភាព។

## ជំហានទី៣៖ ការកំណត់ទីតាំង





- កន្លែងសមរម្យមិនមានមនុស្សចេញចូល និងគ្មានសំឡេងរំខាន
- ជ្រើសរើសបន្ទប់ ដែលមានពន្លឺគ្រប់គ្រាន់ អាចដាក់បណ្ណវាស់គំហើញ មានពន្លឺច្បាស់ល្អ មិនមានចំណាំងផ្លាត
- ជ្រើសរើសបន្ទប់ ដែលអាចដាក់បណ្ណវាស់គំហើញមានចម្ងាយ៣ម៉ែត្រឬ៦ម៉ែត្រ
- ជ្រើសរើសបន្ទប់ មានទីតាំង ដែលកុមារអាចឈរ ឬអង្គុយ។

## ជំហានទី៤៖ ការពន្យល់ណែនាំកុមារ

- បង្កើនភាពស្និទ្ធស្នាលជាមួយកុមារ
- គ្រូត្រូវពន្យល់ណែនាំកុមារពីគោលបំណងនៃការវាស់គំហើញ
- របៀបប្រើប្រាស់បណ្ណវាស់គំហើញ

❖ បង្ហាញរូបភាពឱ្យកុមារមើល រួចសួរកុមារ តើនេះជារូបអ្វី?

❖ ឱ្យកុមារឆ្លើយទៅតាមអ្វីដែលគេយល់ឃើញ (ចម្លើយអ្វីក៏ត្រូវ)











ឧទាហរណ៍៖

❖ ត្រូវយករបាំងគ្របភ្នែកម្តងម្ខាង(ឆ្វេង ឬស្តាំ)

❖ វាស់ភ្នែកកុមារម្នាក់ម្តងៗ

❖ ត្រូវកត់ត្រាលទ្ធផល នៅពេលកំពុងវាស់គំហើញ

## ជំហានទី៥៖ ដំណើរការវាស់គំហើញ

- គណៈគ្រប់គ្រងនិងលោកគ្រូ អ្នកគ្រូ ត្រូវប្រើកម្រងសំណួរ កំណត់អត្តសញ្ញាណស្វែងរកកុមារមានបញ្ហាមើល។
- ប្រសិនបើមានបំណិនគ្រប់គ្រាន់ គណៈគ្រប់គ្រងនិងលោកគ្រូ អ្នកគ្រូ អាចប្រើតារាងលាធាត ឬអ៊ីធាត។

ការកំណត់អត្តសញ្ញាណកុមារ ដោយប្រើ ជម្រើសទី១

កម្រងសំណួរ កំណត់អត្តសញ្ញាណស្វែងរកកុមារមានបញ្ហាមើលៈ

| ល.រ | ភ្នែក និងអាកប្បកិរិយាដែលអាចសម្គាល់ថាមានបញ្ហាមើល | ✓ |
|---|---|---|
| ភ្នែកដែលសម្គាល់ថាមានបញ្ហា | | |
| ១ | ភ្នែកក្រហម | |
| ២ | កញ្ចក់ភ្នែកស្រអាប់ (មិនថ្លា) | |
| ៣ | កូនក្រមុំភ្នែកមិនមានពណ៌ខ្មៅ | |
| ៤ | ភ្នែកទាំងសងខាងមិនធ្វើចលនាព្រមគ្នា | |
| ៥ | ភ្នែកទាំងពីរព្រិចញឹកញាប់ | |
| ៦ | មានដុះសាច់បិទ ឬបាំងភ្នែក | |
| ៧ | ភ្នែកចាញ់ពន្លឺ និងធ្វើចលនាបិទ ឬបើកញាប់ | |
| ៨ | មានស្នាមអុជពណ៌សនៅក្នុង ឬនៅលើផ្នែកខ្មៅនៃភ្នែក | |
| ៩ | ឈឺនៅក្នុងភ្នែក និងមានហៀរទឹកភ្នែក | |
| អាកប្បកិរិយាទាក់ទងនឹងបញ្ហាមើល | | |
| ១០ | ត្អូញឈឺក្បាលក្អួតចង្អោរ ឬវិលមុខពេលសម្លឹងមើលវត្ថុនៅជិត | |
| ១១ | មិនអាចមើលអក្សរ ឬរូបភាពលើក្តារខៀនបើទោះបីអង្គុយនៅជួរទីមួយក៏ដោយ | |
| ១២ | ពិបាកក្នុងការដើរនៅទីកន្លែងថ្មីពុំធ្លាប់ស្គាល់ ឬដើរប៉ះវត្ថុផ្សេងៗ | |
| ១៣ | ត្អូញថាមើលមិនឃើញច្បាស់នៅពេលយប់ | |
| ១៤ | ជ្រួញមុខ ព្រិចភ្នែក ចងចិញ្ចើម នៅពេលដែលខំប្រឹងមើលអ្វីមួយ | |
| ១៥ | ដាក់ក្បាលនៅទីតាំងមិនសមស្រប ឬផ្អៀងទៅម្ខាងពេលប្រឹងមើលអ្វីមួយ | |
| ១៦ | កាន់សៀវភៅអានកៀកនឹងមុខ ឬសរសេរដោយឱនមុខទៅជិតក្រដាស | |
| ១៧ | អាចមើលក្តារខៀន ឬទូរទស្សន៍នៅចម្ងាយជិតៗ | |
| ១៨ | មិនអាចអានទំហំអក្សរនៅក្នុងសៀវភៅពុម្ពបាន | |
| ១៩ | ឧស្សាហ៍យកម្រាមដៃ ឬក្រញ៉ាំដៃរុញគ្រាប់ភ្នែក | |
| ២០ | ធ្លាប់មានការវះកាត់នៅលើភ្នែកម្ខាង ឬទាំងពីរ | |
| កំណត់សម្គាល់៖ ប្រសិនបើមានចំណុចណាមួយមានសញ្ញា (✓) នោះមានន័យថាភ្នែករបស់កុមារអាចមានបញ្ហា។ | | |

ការកំណត់អត្តសញ្ញាណកុមារ ដោយប្រើ ជម្រើសទី២

## ១. ការវាស់ភ្នែក



ក. វាស់ភ្នែកទាំងពីរ របស់កុមារជាមុនសិន ដើម្បីឱ្យកុមារយល់ និងអាចអនុវត្តជំហានបន្ត
ខ. ចំណាត់ថ្នាក់វាស់គំហើញ ដូចខាងក្រោម៖
ប្រសិនបើលទ្ធផលវាស់ឃើញថា

- <6/60 = <3/30 ត្រូវបញ្ជូនបន្ទាន់
- 6/48 = 3/24 ទៅ 6/15 = 3/7.5 ត្រូវបញ្ជូន
- 6/6 = 3/3 ទៅ 6/18 = 3/9 គំហើញធម្មតា

កំណត់សម្គាល់៖

- 6/60 (6 គឺចម្ងាយ6ម៉ែត្រ និង60 គឺទំហំអក្សរ)។
- 3/30 (3 គឺចម្ងាយ3ម៉ែត្រ និង30 គឺទំហំអក្សរ)។

## ជំហានទី៦៖ កំណត់ត្រាលទ្ធផល

កត់ត្រាលទ្ធផលនៃការមើលឃើញរបស់កុមារក្នុងតារាងរបាយការណ៍តាមខ្នាត ទំហំអក្សរធំ ឬតូចដោយគូសសញ្ញាក្នុងប្រអប់ ដូចបង្ហាញក្នុងតារាងឧទាហរណ៍ខាងក្រោម៖

តារាងកំណត់ត្រាលទ្ធផលវាស់គំហើញ

| ល.រ | ឈ្មោះកុមារ | ភេទ | អាយុ | ភ្នែកស្តាំ | | ភ្នែកឆ្វេង | | បញ្ជូន | លេខទូរសព្ទ អ្នកអាណាព្យាបាល |
|---|---|---|---|---|---|---|---|---|---|
| | | | | 6/60 ឬ 3/30 | 6/12 ឬ 3/6 | 6/60 ឬ 3/30 | 6/12 ឬ 3/6 | | |
| ១ | | | | ☐ ខ្សោយគំហើញ | ☐ ធម្មតា | ☐ ខ្សោយគំហើញ | ☐ ធម្មតា | | |
| ២ | | | | ☐ ខ្សោយគំហើញ | ☐ ធម្មតា | ☐ ខ្សោយគំហើញ | ☐ ធម្មតា | | |
| ៣ | | | | ☐ ខ្សោយគំហើញ | ☐ ធម្មតា | ☐ ខ្សោយគំហើញ | ☐ ធម្មតា | | |

ចូរកត់ត្រាលេខទូរសព្ទ អ្នកអាណាព្យាបាលរបស់កុមារ ជាពិសេសកុមារដែលមានបញ្ហាខ្សោយគំហើញ ដើម្បីធ្វើការទំនាក់ទំនងពេលក្រោយ។ ចូរប្រើតារាងទី១ ក្នុងឧបសម្ព័ន្ធ។

## ជំហានទី៧៖ ការបញ្ជូន

- ចូរប្រើតារាងទី២ ក្នុងឧបសម្ព័ន្ធ
- ករណីកុមារមិនអាចមើលឃើញអក្សរអ៊ី(E) (ទំហំ6/60 ឬ 3/30) (ទំហំ6/12 ឬ 3/6) ត្រូវជូនដំណឹងទៅមាតាបិតា ឬអ្នកអាណាព្យាបាល ដើម្បីបញ្ជូនទៅរកសេវាឯកទេសភ្នែក ពិនិត្យ និងព្យាបាល។
- ក្នុងករណីពិនិត្យឃើញថាកុមារមានបញ្ហាណាមួយដូចជា របួសភ្នែក មានវត្ថុចូលក្នុងភ្នែក ឬភ្នែកក្រហម (រាល់ចម្លើយនៅក្នុងកម្រងសំណួរ កំណត់អត្តសញ្ញាណ) ត្រូវបញ្ជូនកុមារទៅរកសេវាឯកទេសភ្នែក ជាបន្ទាន់ ដើម្បីពិនិត្យ និងព្យាបាល។

## ជំហានទី៨៖ ការពិនិត្យតាមដាន



- ចូរប្រើតារាងទី៣ ក្នុងឧបសម្ព័ន្ធ
- បន្ទាប់ពីគ្រូជូនដំណឹងទៅមាតាបិតា ឬអ្នកអាណាព្យាបាល
- គ្រូត្រូវធ្វើការតាមដានស្ថានភាពកុមារដូចខាងក្រោម៖
    - ❖ តើកុមារបានទៅរកសេវាសុខភាពភ្នែកដែរឬទេ?
    - ❖ តើកុមារបានទទួលសេវាសុខភាពភ្នែកដែរឬទេ?
    - ❖ តើកុមារមានប្រើឧបករណ៍ជំនួយភ្នែក (វ៉ែនតា កែវពង្រីក) ដែរឬទេ?
    - ❖ តើឪពុកម្តាយបានអនុវត្តតាមការណែនាំរបស់គ្រូពេទ្យដែរឬទេ?

# ការអនុវត្ត ការកំណត់អត្តសញ្ញាណ កុមារ មានបញ្ហាចលនា

## វត្ថុបំណង៖

- ពង្រឹងសមត្ថភាពគ្រូ ក្នុងការកំណត់អត្តសញ្ញាណកុមារមានបញ្ហាចលនា
- ផ្តល់ព័ត៌មាន និងស្វែងរកសេវាគាំទ្របានសមស្របទាន់ពេលវេលា
- បង្កើន និងពង្រឹងយន្តការនៃការកំណត់អត្តសញ្ញាណកុមារមានបញ្ហាចលនានៅតាមសាលារៀនប្រកបដោយនិរន្តរភាព និងមានគុណភាព។

## ជំហានក្នុងការកំណត់អត្តសញ្ញាណ កុមារមានបញ្ហាចលនា

**ជំហានទី១៖** ការរៀបចំសម្ភារៈ

- ប្រជុំធ្វើផែនការសកម្មភាពជាមួយអ្នកពាក់ព័ន្ធ (មាតាបិតា គ្រូទទួលបន្ទុក នាយកសាលា)
- រៀបចំឧបករណ៍និងសម្ភារៈសម្រាប់កំណត់អត្តសញ្ញាណ

### ជំហានទី២៖ ការរៀបចំបញ្ជីឈ្មោះកុមារ

- បញ្ជីឈ្មោះកុមារដែលសង្ស័យថាមានបញ្ហាចលនា
- លិខិតជូនដំណឹងទៅឪពុកម្តាយ ឬអ្នកអាណាព្យាបាលកុមារ

### ជំហានទី៣៖ ការកំណត់ទីតាំង

- កន្លែងសមរម្យមិនមានមនុស្សចេញចូល និងគ្មានសំឡេងរំខាន
- កន្លែងមានពន្លឺ និងខ្យល់អាកាសគ្រប់គ្រាន់។
- កន្លែងដែលមានផ្ទៃរាបស្មើ

### ជំហានទី៤៖ ការពន្យល់ណែនាំកុមារ

- គ្រូពន្យល់ណែនាំកុមារ ពីគោលបំណងនៃការធ្វើតេស្ត
- លើកទឹកចិត្តកុមារកុំឱ្យភ័យខ្លាច និងមានភាពស្និទស្នាល
- ប្រាប់ពីរបៀបធ្វើចលនាផ្សេងៗតាមការណែនាំរបស់គ្រូ

### ជំហានទី៥៖ ដំណើរនៃការធ្វើតេស្ត

- គ្រូសម្ភាសន៍មាតាបិតា ឬអ្នកអាណាព្យាបាលដើម្បីដឹងពីប្រវត្តិជំងឺខ្លះៗរបស់កុមារ
- គ្រូបង្ហាញកុមារពីរបៀបធ្វើចលនា
- ឱ្យកុមារអនុវត្តតាម
- គ្រូសង្កេតកុមារដោយផ្ទាល់ (ឱ្យកុមារដើរ ឬធ្វើចលនាផ្សេងៗ)
- គ្រូកត់ត្រាលទ្ធផលក្នុងកម្រងសំណួរខាងក្រោម

កម្រងសំណួរ កំណត់អត្តសញ្ញាណ កុមារមានបញ្ហាចលនា

| លរ | សំណួរ | បាទ/ចាស | ទេ |
|---|---|---|---|
| ១ | តើកុមារពិបាកផ្លាស់ទី ឬពិបាកប្រើផ្នែកណាមួយនៃរាងកាយដែរឬទេ? | | |
| ២ | តើកុមារមានខូចទ្រង់ទ្រាយ ឬបាត់បង់អវយវៈណាមួយ ដែលបណ្តាលឱ្យពិបាកធ្វើចលនាដែរឬទេ? | | |
| ៣ | តើកុមារមានប្រវែងជើងមិនស្មើគ្នាដែលបណ្តាលឱ្យពិបាកក្នុងការធ្វើចលនាដែរឬទេ? | | |
| ៤ | តើកុមារពិបាកធ្វើចលនាតូច ចលនាធំដែរឬទេ? ឧទាហរណ៍៖ ពិបាកចាប់កាន់វត្ថុផ្សេងៗ ឡើងចុះជណ្តើរ/កៅអី ឬបិទ/បើកឡេវអាវ... | | |
| ៥ | តើកុមារដើរមានការកន្ត្រាក់សាច់ដុំ ឬដួលភ្លាមៗដែរឬទេ? | | |
| កំណត់សម្គាល់៖ ប្រសិនបើមានចម្លើយ "បាទ ឬចាស" ចំនួន១ នោះកុមារមានបញ្ហាចលនា។ | | | |





ឧបករណ៍ លម្អិត ជំនួយស្មារតី សម្រាប់ការកំណត់អត្តសញ្ញាណកុមារ មានបញ្ហាចលនា ឬកាយសម្បទា៖

១. កុមារមានផ្នែកណាមួយនៃអវយវៈត្រូវបានបាត់បង់



ដាច់អវយវៈលើ ដាច់អវយវៈក្រោម ប្រើប្រាស់រទេះរុញ

២. កុមារមានកំហូចរាង ឬភាពមិនប្រក្រតីណាមួយនៃអវយវៈ












ស្វិតដៃជើង



អវយវៈខុសប្រក្រតីពីកំណើត




៣. កុមារមានប្រវែងជើងមិនស្មើគ្នា



ការវាស់ ដោយដាក់កំណល់




## ជំហានទី៦៖ ការកត់ត្រាលទ្ធផល

- ចូរកត់ត្រាលទ្ធផលនៃការធ្វើតេស្តដោយប្រើតារាងទី១ក្នុងឧបសម្ពន្ធ។

## ជំហានទី៧៖ ការបញ្ជូន

- ចូរប្រើតារាងទី២ក្នុងឧបសម្ពន្ធ
- ករណីរកឃើញកុមារសង្ស័យថាមានបញ្ហា ត្រូវជូនដំណឹងទៅមាតាបិតា ឬអ្នកអាណាព្យាបាលដើម្បីបញ្ជូនទៅរកសេវាគាំទ្រសមស្របនានា

- ក្នុងករណី គ្រូពេទ្យឯកទេសបានកំណត់រកឃើញកុមារមានបញ្ហាចលនាត្រូវបញ្ជូនទៅរកសេវាគាំទ្រសមស្រប ផ្សេងៗ នៅតាមមន្ទីរពេទ្យ មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្ម ឬដៃគូអភិវឌ្ឍនានា។
- បំពេញលិខិតជូនដំណឹង និងលិខិតបញ្ជូនទៅរកសេវាគាំទ្រ។

## ជំហានទី៨៖ ការពិនិត្យតាមដាន

ចូរប្រើតារាងទី៣ក្នុងឧបសម្ពន្ធ។សាលារៀន និងអ្នកអាណាព្យាបាលតាមដានស្ថានភាពកុមារដូចខាងក្រោម៖

- តើកុមារបានទៅរកសេវាសុខភាព ឬសេវាស្តារលទ្ធភាពពលកម្មកាយសម្បទា ដែរឬទេ ?
- តើកុមារបានទទួលសេវាសុខភាពសេវាស្តារលទ្ធភាពពលកម្មកាយសម្បទា អ្វីខ្លះ ?
- តើកុមារបានទទួលការពិនិត្យតាមដានសុខភាពនិងការវិវឌ្ឍនៃការស្តារលទ្ធភាពពលកម្មកាយសម្បទាជាប្រចាំ ដែរឬទេ ?
- តើកុមារមានប្រើប្រាស់ឧបករណ៍ជំនួយកាយសម្បទា (ឈើច្រត់ រទេះរុញ ដៃឬជើងសិប្បនិម្មិត ...) ដែរឬទេ ?
- តើមានការកត់ត្រាពីការវិវឌ្ឍរបស់កុមារបន្ទាប់ពីការទទួលបានសេវាសុខភាព ឬសេវាស្តារលទ្ធភាព ពលកម្មកាយសម្បទា ដែរឬទេ ?



# ឧបសម្ពន្ធ

## ឧបសម្ពន្ធ១៖ ដ្យាក្រាម ជំហាននៃការកំណត់អត្តសញ្ញាណកុមារមានពិការភាព

↓

ជំហានទី១៖ រៀបចំសម្ភារៈសម្រាប់អនុវត្តការកំណត់អត្តសញ្ញាណ

↓

ជំហានទី២៖ រៀបចំបញ្ជីឈ្មោះកុមារ

↓

ជំហានទី៣៖ រកទីកន្លែង

↓

ជំហានទី៤៖ ពន្យល់ណែនាំកុមារ (វិធីសាស្ត្រអនុវត្តការធ្វើតេស្ត)

↓

ជំហានទី៥៖ អនុវត្តការធ្វើតេស្ត

↓

ជំហានទី៦៖ កត់ត្រាលទ្ធផល

↓

ជំហានទី៧៖ ជូនដំណឹង ឬបញ្ជូន

↓

ជំហានទី៨៖ តាមដាន

# ឧបសម្ពន្ធ២៖ សេវាសម្រាប់កុមារ មានពិការភាព និងជនមានពិការភាព

| ក. ផ្នែកថែទាំវេជ្ជសាស្ត្រ និងព្យាបាល | | |
|---|---|---|
| ១ | ឈ្មោះអង្គភាព | អង្គការសុខភាពត្រចៀកនៅកម្ពុជា ( ALL EAR Cambodia ) |
| | អាសយដ្ឋាន | ផ្ទះលេខ ១០៩z ផ្លូវលេខ ២២៨ ខណ្ឌដូនពេញ សង្កាត់ចតុមុខ ភ្នំពេញ |
| | ទូរស័ព្ទ | ០៨៧ ៥២៨ ៦១៧/ ០១២ ៦៣០ ១៩៧/ ០១២ ៦២៤ ៥៣០ |
| | ប្រភេទសេវាកម្ម | ពិនិត្យ ព្យាបាល ផ្តល់ឧបករណ៍ជំនួយត្រចៀក |
| ២ | ឈ្មោះអង្គភាព | មន្ទីរពេទ្យភ្នែកខេត្តតាកែវ |
| | អាសយដ្ឋាន | ភូមិផ្សារតាកោ ឃុំរកាក្នុង ស្រុកដូនកែវ ខេត្តតាកែវ |
| | លេខទូរស័ព្ទ | ០៣២ ៩៣១ ៣២៤/០១៦ ៣២០ ០៦៦ |
| | សេវាកម្ម | ពិនិត្យ ព្យាបាល វះកាត់ ផ្តល់វ៉ែនតា កំណត់អត្តសញ្ញាណពិការភ្នែក |
| ៣ | ឈ្មោះអង្គភាព | អង្គការ OPBG ( អ៊ីតាលី ) |
| | អាសយដ្ឋាន | ភូមិឡូរី ឃុំរកាក្នុង ស្រុកដូនកែវ ខេត្តតាកែវ |
| | ទូរស័ព្ទ | ០៣២ ៦៤០ ៣៣៨១ |
| | ប្រភេទសេវាកម្ម | ពិនិត្យ និងព្យាបាលកុមារ |
| ៤ | ឈ្មោះអង្គភាព | មជ្ឈមណ្ឌលសុខភាពផ្លូវចិត្តកុមារ និងមនុស្សពេញវ័យ ( CCAMH ) |
| | អាសយដ្ឋាន | ផ្លូវជាតិលេខ២ មន្ទីរពេទ្យជ័យជំនះ ក្រុងតាខ្មៅ ខេត្តកណ្តាល |
| | ទូរស័ព្ទ | ០២៣ ៣០០ ៥៣៤ ០១១ ៨៧ ៨១ ៥៨ |
| | ប្រភេទសេវាកម្ម | ផ្តល់ការថែទាំវេជ្ជសាស្ត្រ សម្រាប់កុមារមានពិការភាព កំណត់អត្តសញ្ញាណ និងការព្យាបាលវេជ្ជសាស្ត្រ |

## ខ. ផ្នែកសេវាស្តារលទ្ធភាពពលកម្ម

| ល.រ | ពណ៌នា | ព័ត៌មានលំអិត |
|---|---|---|
| ១ | ឈ្មោះអង្គភាព | ហេបភីគ្លីនិក ( Happy Kids Clinic ) |
| | អាសយដ្ឋាន | ផ្ទះលេខ ២៨ ផ្លូវឧកញ៉ា ជ្រុន យូហាក់ (ផ្លូវលេខ ២៩៤), បឹងកេងកង ១ ភ្នំពេញ |
| | ទូរស័ព្ទ | ០៧៧ ៧១៥ ៥៧៨ |
| | ប្រភេទសេវាកម្ម | ព្យាបាលដោយចលនា សម្រាប់កុមារមានបញ្ហានិយាយ |
| ២ | ឈ្មោះអង្គភាព | មជ្ឈមណ្ឌលវះកាត់កុមារ ( CSC ) |
| | អាសយដ្ឋាន | មណ្ឌលស្តារលទ្ធភាពជនពិការ គៀនឃ្លាំង ភ្នំពេញ |
| | ទូរស័ព្ទ | ០២៣ ៤៣០ ២០២/ ០១២ ៨០៧ ៦៧៩ |
| | ប្រភេទសេវាកម្ម | បញ្ហាមើល និយាយ និងបញ្ហាស្តាប់ |
| ៣ | ឈ្មោះអង្គភាព | មជ្ឈមណ្ឌល ស្តារលទ្ធភាពពលកម្ម ខេត្តកំពង់ស្ពឺ |
| | អាសយដ្ឋាន | ភូមិអង្គសេរី ឃុំរកាធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ (មណ្ឌលស្តារមានទីតាំងស្ថិតនៅក្នុងមន្ទីរពេទ្យបង្អែក ខេត្តកំពង់ស្ពឺ ) |
| | លេខទូរស័ព្ទ | ០២៥ ៩៨៧ ១៥៩/០៨៩ ៩៥២ ២៦៩ |
| | សេវាកម្ម | ស្តារលទ្ធភាពពលកម្ម ផ្តល់ឧបករណ៍ជំនួយ ដល់ជនមានពិការភាព |
| ៤ | ឈ្មោះអង្គភាព | មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មខេត្តតាកែវ |
| | អាសយដ្ឋាន | ផ្លូវលេខ១៤ ភូមិ១៣ ឃុំរកាក្នុង ស្រុកដូនកែវ ខេត្តតាកែវ |
| | លេខទូរស័ព្ទ | ០៣២ ៩២១ ២៩៣/០៩៧ ៨៨៦៤ ៦៩០ |
| | សេវាកម្ម | ស្តារលទ្ធភាពពលកម្ម ផ្តល់ឧបករណ៍ជំនួយដល់ជនមានពិការភាព |
| ៥ | ឈ្មោះអង្គភាព | អង្គការអតីតយុទ្ធជន អន្តរជាតិកម្ពុជា ( VIC ) |
| | អាសយដ្ឋាន | ភូមិគៀនឃ្លាំង សង្កាត់ជ្រោយចង្វា ខ័ណ្ឌឫស្សីកែវ ភ្នំពេញ |
| | ទូរស័ព្ទ | ០២៣ ៤៣០ ៣០៥ |
| | ប្រភេទសេវាកម្ម | ស្តារកាយសម្បទា កំណត់រាល់ប្រភេទពិការ ផ្តល់ការព្យាបាល និង ឧបករណ៍ជំនួយ ចុះតាមសហគមន៍ សម្រាប់ក្រុមជួយខ្លួនឯង |

| | | |
|---|---|---|
| ៦ | ឈ្មោះអង្គភាព | អង្គការអិចស៊ីត វើលវ៉ាយ Exceed Worldwide |
| | អាសយដ្ឋាន | ផ្ទះលេខ២២ ផ្លូវដួងលាភពីរ សង្កាត់មានជ័យ ខ័ណ្ឌមានជ័យ ភ្នំពេញ |
| | ទូរស័ព្ទ | ០១២ ៨៩៤ ៤៤៦; ០១២ ៥១៤ ០៥៦ |
| | ប្រភេទសេវាកម្ម | ស្តារកាយសម្បទា ផ្តល់ឧបករណ៍ជំនួយ ការព្យាបាល ការធ្វើដំណើរ ការហ្វឹកហ្វឺន សម្រាប់កុមារមានពិការភាព |
| ៧ | ឈ្មោះអង្គភាព | Khmer Sight Foundation |
| | អាសយដ្ឋាន | ផ្ទះលេខ ៩៣ ផ្លូវនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ |
| | ទូរស័ព្ទ | ០៨៥ ៨៦៦ ៦៥០/ ០៧០ ៨២៤ ២២២ |
| | ប្រភេទសេវាកម្ម | បញ្ហាភ្នែក (ព្យាបាល វះកាត់ និងផ្តល់វ៉ែនតា) |

# ឧបសម្ព័ន្ធ៣៖

## របាយការណ៍លទ្ធផល នៃការកំណត់អត្តសញ្ញាណ កុមារមានពិការភាព

បញ្ជីឈ្មោះកុមារ ដែលសង្ស័យថាមានភាពកម្សោយ ឬមានពិការភាព (ក្នុងជំហានទី៦)

សាលាបឋមសិក្សា៖.......................................................ឃុំ/សង្កាត់...................ក្រុង/ស្រុក/ខណ្ឌ...............

| ល.រ | ឈ្មោះ | ភេទ | អាយុ | កម្រិតថ្នាក់ | សង្ស័យថាមានភាពកម្សោយឬភាពពិការភាពផ្នែក | ឈ្មោះអ្នកអាណាព្យាបាលលេខទូរស័ព្ទទំនាក់ទំនង | អាសយដ្ឋានរស់នៅសព្វថ្ងៃ |
|---|---|---|---|---|---|---|---|
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

ថ្ងៃ...........ខែ..........ឆ្នាំ.....................................ព.ស២៥៦...

...ថ្ងៃទី...........ខែ...........ឆ្នាំ២......

នាយក/នាយិកា

# ឧបសម្ព័ន្ធ៤៖ បញ្ជីឈ្មោះកុមារ ត្រូវបញ្ជូនទៅរកសេវា

## បញ្ជីឈ្មោះកុមារ ដែលត្រូវបញ្ជូនទៅរកសេវាគាំទ្រ (ក្នុងជំហានទី៧)

សាលាបឋមសិក្សា៖.....................ឃុំ/សង្កាត់...................ក្រុង/ស្រុក/ខណ្ឌ...............រាជធានី/ខេត្ត......

| ល.រ | ឈ្មោះ | ភេទ | អាយុ | កម្រិតថ្នាក់ | សង្ស័យថាមានភាពកម្សោយឬពិការភាពផ្នែក | ឈ្មោះ អ្នកអាណាព្យាបាល លេខទូរស័ព្ទ ទំនាក់ទំនង | ឈ្មោះស្ថាប័នផ្ដល់សេវា លេខទូរស័ព្ទ ទំនាក់ទំនង | បញ្ជូនលើកទី |
|---|---|---|---|---|---|---|---|---|
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |

ថ្ងៃ..........ខែ..........ឆ្នាំ.....................................ព.ស២៥៦...

...ថ្ងៃទី..........ខែ..........ឆ្នាំ២......

នាយក/នាយិកា

# ឧបសម្ពន្ធ៥៖ លិខិតជូនដំណឹង គំរូទី១ និងទី២

## លិខិតជូនដំណឹង គំរូទី១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**មន្ទីរអប់រំ យុវជន និងកីឡារាជធានី/ខេត្ត..........................**

**ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង/ស្រុក/ខណ្ឌ..............**

**ឈ្មោះអង្គភាព.............................................................**

### លិខិតជូនដំណឹង

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ..................................ជាគ្រូមត្តេយ្យសិក្សានៅសាលា....................................។

### សូមជម្រាបជូន

លោក/លោកស្រីដែលជាអ្នកអាណាព្យាបាលកុមារឈ្មោះ..........................................រៀននៅថ្នាក់មត្តេយ្យសិក្សានៃសាលា............................................ឱ្យបានជ្រាបថាបន្ទាប់ពីបានធ្វើតេស្តលើបញ្ហានិយាយ យើងរកឃើញថាកូនរបស់លោក/លោកស្រីមានបញ្ហា៖..........................................................ដែលតម្រូវឱ្យលោក/លោកស្រី ត្រូវតែបញ្ជូន និងនាំកូនទៅរកសេវាគាំទ្រផ្នែក៖......................................។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោក/លោកស្រី សហការជាមួយសាលារៀន ដើម្បីជួយបញ្ជូននិងនាំកូនទៅរកសេវាគាំទ្រ ឱ្យបានទាន់ពេលវេលា កុំបីអាក់ខានឡើយ ។

ថ្ងៃ..........ខែ.........ឆ្នាំ...............................ព.ស២៥៦...

...ថ្ងៃទី..........ខែ..........ឆ្នាំ២......

**នាយក/នាយិកា**

សូមលោក លោកស្រីមេត្តាផ្តល់ព័ត៌មានត្រឡប់មកសាលារៀន ដោយបំពេញចន្លោះនៅខាងក្រោម៖

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ........................................................ត្រូវជាមាតាបិតា ជាអាណាព្យាបាល

☐ យល់ព្រម ☐ មិនយល់ព្រម បញ្ជូនកូនទៅរកសេវា............................................................។

សូមទំនាក់ទំនងសម្រាប់ព័ត៌មានលម្អិត(លេខទូរសព្ទ......................................................................)

ហត្ថលេខា ឬស្នាមមេដៃអ្នកអាណាព្យាបាលកុមារ

ឈ្មោះ.......................................

## លិខិតជូនដំណឹង គំរូទី២

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**មន្ទីរអប់រំ យុវជន និងកីឡារាជធានី/ខេត្ត...........................**

**ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង/ស្រុក/ខណ្ឌ..............**

**ឈ្មោះអង្គភាព....................................................................**

## លិខិតជូនដំណឹង

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.........................................ជាគ្រូមត្តេយ្យសិក្សានៅសាលា.................................

## សូមជម្រាបជូន

លោក/លោកស្រីដែលជាអ្នកអាណាព្យាបាលកុមារឈ្មោះ...................................រៀននៅថ្នាក់មត្តេយ្យសិក្សានៃសាលា...............................ឱ្យបានជ្រាបថា បន្ទាប់ពីបានធ្វើតេស្តលើបញ្ហានិយាយ យើងរកឃើញថាកូនរបស់លោក/លោកស្រី មានបញ្ហា៖ បញ្ហានិយាយក្ងួរ និយាយគ្រដិត ឬជំឡាន់ មានការលូតលាស់ផ្នែកនិយាយ និងភាសាយឺតយ៉ាវ បញ្ហាឆែបមាត់ បញ្ហាឆែបក្រអូមមាត់ បញ្ហាផ្នែកបញ្ចេញសំឡេង   បញ្ហាផ្សេងៗទៀត........................ ...................................................... ដែលតម្រូវឱ្យលោក/លោកស្រី ត្រូវតែនិយាយលេងជាមួយកូនឱ្យបានច្រើន និងនាំកូនទៅរកសេវាគាំទ្រ.............................

..........................................................................................................................................។
អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោក/លោកស្រី មេត្តាជួយដល់កូនរបស់លោកអ្នកបានទាន់ពេលកុំបីខាន ។

ថ្ងៃ...........ខែ..........ឆ្នាំ................................ព.ស២៥៦...

...ថ្ងៃទី...........ខែ...........ឆ្នាំ២......

**នាយក/នាយិកា**

# ឧបសម្ព័ន្ធ៦៖បញ្ជីតាមដានកុមារមានពិការភាព

បញ្ជីតាមដានកុមារមានពិការភាព (ក្នុងជំហានទី៨)

សាលាបឋមសិក្សា៖......................ឃុំ/សង្កាត់....................ក្រុង/ស្រុក/ខណ្ឌ................រាជធានី/ខេត្ត......

| ល.រ | ឈ្មោះ | ភេទ | អាយុ | កម្រិតថ្នាក់ | ភាពកម្សោយឬពិការភាពផ្នែក | ឈ្មោះអ្នកផ្តល់សេវា | រោគវិនិច្ឆ័យ កំណត់ដោយគ្រូពេទ្យ ឬវេជ្ជបណ្ឌិត | ដំបូន្មានគ្រូពេទ្យ ឬវេជ្ជបណ្ឌិត | កាលបរិច្ឆេទបញ្ជូន លើកទី..... | កាលបរិច្ឆេទ បញ្ជូនលើកក្រោយ | ការវិវឌ្ឍ របស់កុមារក្រោយពេលបញ្ជូន |
|---|---|---|---|---|---|---|---|---|---|---|---|
| | ឧទាហរណ៍ | | | | | | | | | | |
| ១ | ក | ប | ៥ | | | គ្រូសារថ្មី | គថ្លង់ | ប្រើម៉ាស៊ីនជំនួយស្តាប់ត្រចៀកឆ្វេង | ១១/១/១៩ | ១១/៥/១៩ | ការស្តាប់បានប្រសើរជាងមុន |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |

# ក្រសួងអប់រំ យុវជន និងកីឡា
# និង
# អង្គការ កាតូលិក រីលីស ស៊ីវិស (ស៊ីអារអេស)

សូមថ្លែងអំណរគុណ

ចំពោះដៃគូអភិវឌ្ឍ ក្នុងការចងក្រងឯកសារ ការកំណត់អត្តសញ្ញាណកុមារមានពិការភាព

អាយុក្រោម ៦ឆ្នាំសម្រាប់ជំនួយស្មារតីគ្រូមត្តេយ្យសិក្សា

- អង្គការអេអេអារ ជប៉ុន AAR-Japan
- មជ្ឈមណ្ឌល CCAMH នៃអង្គការ ការីតាសកម្ពុជា
- មន្ទីរពេទ្យភ្នែក តាកែវ នៃអង្គការ ការីតាសកម្ពុជា
- អង្គការជំនួយនៃក្តីសង្ឃឹមសម្រាប់សហគមន៍ Hand of Hope Community
- អង្គការ Humanity and Inclusion ( HI )
- អង្គការគ្រួសារថ្មី Krousar Thmey
- អង្គការមូលនិធិកុមារពិការ Komar Pikar Foundation
- អង្គការ OiC កម្ពុជា
- អង្គការ សាលារៀនទន្សាយ Rabbit School Organization